# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ អ៊ូ គីម ហៅ រ៉េត ភេទប្រុស អាយុ៥៩ឆ្នាំ**

**មុខរបរក្នុងសម័យខ្មែរក្រហមៈ កងទ័ពក្នុងកងពល១៦៤ ឈរជើងនៅកោះពូលូវ៉ៃ**

**ទីកន្លែងកំណើតៈ ភូមិសូរិយា ឃុំត្នោតចុងគ្រង់ ស្រុកបន្ទាយមាស ខេត្តកំពត**

**សព្វថ្ងៃរស់នៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង**

**សម្ភាសន៍ដោយៈ ឡុង ដានី និង សុខ វណ្ណះ**

**ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥**

**រយះពេលៈ ០១:២២:១០**

**ទំព័សរុបៈ ៤៨ ទំព័រ**

អ៊ូ គីមៈ មុន មុនអើ! ហ្នឹងសម្ភាសន៍ តើអូនឯងចង់ឲ្យខ្ញុំនិយាយពីបញ្ហាអី? កាលណាសួរ....

សុខ វណ្ណះៈ អត់! អត់អីទេពូ! ចាំមើលខ្ញុំសួរទៅ ពូអាចឆ្លើយយ៉ាងម៉េចបាន?

អ៊ូ គីមៈ អ៊ូ! អញ្ចឹង!

សុខ វណ្ណះៈ បាទ! បានតាមហ្នឹងណា! ពូណា! បាទ! មិនអីទេ។

សុខ វណ្ណះៈ អញ្ចឹង! ខ្ញុំសូមណែនាំខ្លួនថា ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំឈ្មោះ សុខ វណ្ណះ ហើយនេះ ឈ្មោះ ឡុង ដានី។ ហើយ ខ្ញុំបានមកភូមិឃុំរបស់ពូហ្នឹង គឺខ្ញុំចង់បានព័ត៌មានមួយចំនួនទាក់ទងនៅក្នុងសម័យ៣ឆ្នាំ៨ខែហ្នឹងណា។ នៅក្នុងរបបខ្មែរក្រហម របបកម្ពុជាប្រជាធិបតេយ្យហ្នឹង។ ជាដំបូង ខ្ញុំចង់ស្គាល់ឈ្មោះពូ។ តើពូឈ្មោះអីដែរ?

អ៊ូ គីមៈ បាទ! ខ្ញុំបាទឈ្មោះ អ៊ូ គីម។

សុខ វណ្ណះៈ អ៊ូ គីម!

អ៊ូ គីមៈ បាទ! សព្វថ្ងៃ នៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

សុខ វណ្ណះៈ បាទ! នៅភូមិអូរ ឃុំសន្តិភាព។ បាទ! ពូមានឈ្មោះហៅក្រៅទៀតទេពូ? ឈ្មោះផ្សេងទៀត។

អ៊ូ គីមៈ បាទ! ហៅក្រៅ គេហៅថា រ៉េត។ រ៉េត ហ្នឹង!

សុខ វណ្ណះៈ បាទ! ចុះ! កាលពីនៅតូច ពូ នៅស្រុកកំណើតពូ គឺនៅ នៅក្នុងភូមិឃុំអីដែរ?

អ៊ូ គីមៈ បាទ! អើ! ពីមុនស្រុកកំណើតខ្ញុំនៅភូមិសូរិយា ឃុំត្នោតចុងគ្រង់ ស្រុកបន្ទាយមាស ខេត្តកំពត។ ហើយខ្ញុំបានចេញមកធ្វើជាទាហាន អើ! តស៊ូហ្នឹង! នៅឆ្នាំ៧២ ខែ១០ អ៊ូ! ខែ២។ ឆ្នាំ៧២ ខែ២ ខ្ញុំក៏ចេញពីផ្ទះហ្នឹងមកបង្កើតជាទ័ព។

សុខ វណ្ណៈ បា៎ទ! ខ្ញុំចង់សួរបញ្ជាក់បន្ថែមបន្តិចត្រង់ថា កាលពីតូចហ្នឹង ពូបានរៀនសូត្រអីដែរ? កាលនៅតូចៗ ធំដឹងក្ដីមក នៅជាមួយឪពុកម្ដាយហ្នឹងៗ បានចូលរៀនសាលាដែរ?

អ៊ូ គីមៈ បា៎ទ!

សុខ វណ្ណៈ រៀនបានថ្នាក់ណា? ត្រឹមទីប៉ុន្មានដែរ?

អ៊ូ គីមៈ បា៎ទ! ខ្ញុំ ខ្ញុំ ពីដើមខ្ញុំធ្លាប់បានរៀនដល់ថ្នាក់ទី១០ពីសង្គមចាស់ៗ

សុខ វណ្ណៈ ទី១០ «ចាស់»?

អ៊ូ គីមៈ បាទ!

សុខ វណ្ណៈ បា៎! ហើយ ឪពុកពូឈ្មោះអីដែរ?

អ៊ូ គីមៈ ឪពុកខ្ញុំឈ្មោះ អ៊ិនៗ ម្ដាយខ្ញុំឈ្មោះ ហាក់ៗ មាស ហាក់ៗ

សុខ វណ្ណៈ បា៎ទ! ពូមានបងប្អូនទាំងអស់ប៉ុន្មាននាក់ បងប្អូនបង្កើត?

អ៊ូ គីមៈ ៩ ទាំងអស់៩នាក់ៗ

សុខ វណ្ណៈ បា៎ទ! ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរ?

អ៊ូ គីមៈ ស្រី៣ ប្រុស៦ៗ

សុខ វណ្ណៈ បា៎ទ! ចុះពូ! ការដែលថា ម៉េចបានពូ មានចិត្តចូលចលនា ខាងខ្មែរក្រហមហ្នឹង ឆ្នាំ១៩៧២ ម៉េចបានពូ ចង់ចូល ឬក៏មានគេបង្ខំ ឬក៏យ៉ាងម៉េចដែរកាលហ្នឹង? ឬក៏ពូយល់ឃើញដោយខ្លួនឯង ឬក៏យ៉ាងម៉េចពូ?

អ៊ូ គីមៈ បា៎ទ! ចំណុច! ពីមុនវានៅក្មេង ដូច្នេះ វាខ្វះការគិតគូរៗ ហើយឃើញគេមកអីចឹង ភ្លូកភ្លឹកអីចឹងទៅ ពីមុនវា ខ្វះការត្រិះរិះពិចារណាក៏មកជាមួយគេមកៗ

សុខ វណ្ណៈ អត់មានពីណាបង្ខំទេ យើងចង់ចូលទៅហ្នុងៗ

អ៊ូ គីមៈ បា៎ទ! អត់ទេ!

សុខ វណ្ណៈ បា៎ទ! ពូចូលដំបូងហ្នឹង ដូចថា មេឃុំមេភូមិអូសទាញ ឬក៏ស្ដាប់តាមការប្រកាសរបស់សម្ដេច ពីប៉េកាំងឬក៏យ៉ាងម៉េចដែរកាលហ្នឹង?

អ៊ូ គីមៈ តាមពិត ពីដំបូង គ្មានអ្នកណាគេអូសទាញទេអូនៗ កាលហ្នឹង វាមាន ខាងឈ្លបឃុំ ឈ្លបអញ្ចឹង! ជាក្មេងៗដូចគ្នាហ្នឹងៗ ដល់ពេលនេះវា តាមរយៈហ្នឹង ក៏បបួលគ្នាថា ហ្អ៎! ហ្អែ៎ងទៅផ្ដើកងទ័ពកងឈ្លបអីហ្នឹង ក៏មកតាមគ្នាបណ្ដោយៗ

សុខ វណ្ណៈ បា៎ទ! ចាប់ពីឆ្នាំ៧០ រដ្ឋប្រហារហើយ នៅភូមិឃុំពូហ្នឹង កន្លែងហ្នឹងជាតំបន់ប្រទាញប្រទង់ ឬក៏ជាតំបន់រំដោះ ឬក៏ជាតំបន់ខាងលន់ នល់កាលហ្នឹង?

អ៊ូ គីម:	បាទ! ក្រោយពីកាលឆ្នាំ៧០មក គឺជាវាប្រទាញប្រទង់គ្នា ។ ប្រទាញប្រទង់ទាហាន ម្ខាងទៅ ទ័ពខ្មែរក្រហមម្ខាងអញ្ចឹងទៅ វ៉ៃគ្នាញឹកញាប់អី មួងម្កាលអញ្ចឹង ។

សុខ វណ្ណះ:	បាទ! ពេលពូចូលដំបូង ពូចូលទៅនៅម្តុំណា? ចូលដំបូង?

អ៊ូ គីម:	បាទ! កាលដំបូង ខ្ញុំចូលទៅហ្នឹង ចូលក្នុងទ័ពស្រុក ស្រុកបន្ទាយមាស ខេត្តកំពត ។

សុខ វណ្ណះ:	បាទ! កាលហ្នឹង ប្រធានអី ឈ្មោះអីដែរប្រធាន?

អ៊ូ គីម:	អូ! ប្រធាន!

សុខ វណ្ណះ:	ប្រធានយោធា ប្រធានយោធាស្រុកអីចឹង?

អ៊ូ គីម:	កាលហ្នឹង ឈ្មោះ សាវ៉ែន ។

សុខ វណ្ណះ:	បាទ!

អ៊ូ គីម:	ឈ្មោះ សាវ៉ែន ។

សុខ វណ្ណះ:	ចុះឥឡូវគាត់នៅណា?

អ៊ូ គីម:	មិនដឹងថាយ៉ាងម៉េចទេអូន បើបាត់យូរហើយ ។

សុខ វណ្ណះ:	បាទ! ពូចូលជាយោធាស្រុកហើយ បន្តទៅខាងមុខម៉េចទៀត ដូចថាឡើងទៅសមរភូមិ ឬក៏នៅយោធាស្រុករហូតដល់បែក៧៥ហ្នឹង ឬយ៉ាងម៉េច?

អ៊ូ គីម:	ក្រោយពីខ្ញុំនៅស្រុកបានប្រហែលជា១ឆ្នាំ ឬ២ឆ្នាំចុះ ថា២ឆ្នាំ ខ្ញុំហ្នឹងឡើងមកតំបន់ ។ មកកងយោធាតំបន់ ។

សុខ វណ្ណះ:	តំបន់ប៉ុន្មាន?

អ៊ូ គីម:	តំបន់ហ្នឹង! តំបន់៣៥ ។ នៅពីខាងកើតកំពត ។ ខ្ញុំបានធ្វើអន្តរគមន៍នៅខាងកើតកំពតហ្នឹង ។

សុខ វណ្ណះ:	ពូឡើងមកតំបន់ហ្នឹង គេបានបែងចែកជាកងពល កងអីនៅ ពូឡើងមកដល់ហ្នឹង?

អ៊ូ គីម:	កងពលហ្នឹង គេបែងចែកជាកងពលហើយ ។ កងពលពីខាងកើតកំពតហ្នឹង តែលេខកងពលខ្ញុំភ្លេចបាត់ហើយ ។ ខ្ញុំដឹងវរៈ គឺវរៈ៥៧ មានឈ្មោះ ជាវ ជាប្រធានវរៈ ។

សុខ វណ្ណះ:	បាទ! វរៈ៥៧! វរសេនាធំ ឬវរសេនាតូច?

អ៊ូ គីម:	វរសេនាតូច៥៧ ។

សុខ វណ្ណះ:	បាទ! ចុះវរសេនាធំដឹងទេ?

អ៊ូ គីម:	វរសេនាធំ ខ្ញុំវាភ្លេចទៅ ។

សុខ វណ្ណះ:	ចុះមានចាំឈ្មោះប្រធានកងពលទេកាលហ្នឹង?

អ៊ូ គីម:	អត់ចាំទេ អត់ អត់ចាំ ។

សុខ វណ្ណៈ  បាទ! ចុះពូ ខ្ញុំ! ដូចថាពូនៅហ្នឹង កាលហ្នឹង វាយប្រយុទ្ធជាមួយទាហានលន់ នល់ មែន?

អ៊ូ គីមៈ  បាទ!

សុខ វណ្ណៈ  បាទ! ពូបានវាយនៅចល័តនៅកន្លែងណាខ្លះ បានរហូតបានដល់ឆ្ងាយបែកទីក្រុងភ្នំពេញ ពូបានមកដែរអត់? ឬក៏នៅក្នុងហ្នឹង នៅខេត្តហ្នឹង?

អ៊ូ គីមៈ  អើ! តាមពិត ខ្ញុំធ្វើនៅកងតំបន់ហ្នឹង គេហៅថាតំបន់៣៥ នៅពីខាងកើតកំពតហ្នឹង ។ ខ្ញុំបានចល័តវៃម៉ាដួរខាងត្បូងកំពត ហើយពីខាងកើតកំពត ពីខាងជើងកំពត ។ រួចមកគេក៏បញ្ជូនខ្ញុំឡើងមកកង ហៅថាកងមជ្ឈិម នៅកំពង់សោមនេះ ។ ខ្ញុំនៅកំពង់សោមហ្នឹង ពីមុនគេបញ្ជូនទៅ ទៅនៅរាមបានប្រហែលជា១ខែ-២ខែ ។ ហាត់នៅហ្នឹង ហើយបានជាគេបញ្ជូនខ្ញុំឡើងទៅតាមកោះ ។

សុខ វណ្ណៈ  បាទ! បែកឈ្នះលន់ នល់ហើយ?

អ៊ូ គីមៈ  បាទ! ឈ្នះហើយ ។

សុខ វណ្ណៈ  ៧៥ហើយ!

អ៊ូ គីមៈ  បាទ!

សុខ វណ្ណៈ  ៧៥ហើយភ្លាម ពូអត់បានចូលភ្នំពេញទេអញ្ចឹង គឺទៅខាងកងទឹកបញ្ជូនទៅខាងកំពង់សោមវិញ ។

អ៊ូ គីមៈ  បាទ!

សុខ វណ្ណៈ  ដល់ពេលទៅដល់កំពង់សោមហ្នឹង អ្នកណាប្រធានកងពលនៅហ្នឹង?

អ៊ូ គីមៈ  ប្រធានកងពលកាលហ្នឹងមាន ឈ្មោះ តាមុត ។

សុខ វណ្ណៈ  តាមុត! ហើយមានពីណាទៀត?

អ៊ូ គីមៈ  តាមុត ហើយ! មិនដឹងច្បាស់មាន តាមុត មួយ ហើយហ្នឹង តាម៉េត មួយទៀត ។ តាម៉េត ហើយលោក សារឿន ដែលស្លាប់បាត់នេះ ។ ខ្ញុំដឹងតែប៉ុណ្ណឹង ។

សុខ វណ្ណៈ  មានឈ្មោះឌឹមអីទេ? តាឌឹម?

អ៊ូ គីមៈ  ហ្នឹងដូចមានដែរ ។ តែខ្ញុំមិនចាំ ខ្ញុំមិនហ៊ាននិយាយទេអាចំណុចហ្នឹង ។

សុខ វណ្ណៈ  តាម៉េត! ម៉េចគាត់នៅខាងកំពង់សោមហ្នឹងដែរ?

អ៊ូ គីមៈ  បាទ! បងម៉េត គាត់នៅម្ដុំកំពង់សោមហ្នឹងដែរ ។

ឡុង ដានីៈ  ម៉េត ណា? ស៊ូ ម៉េត មែនទេ?

អ៊ូ គីមៈ  ម៉េត ខ្វាក់ម្ខាង ។

សុខ វណ្ណះ: អ៊ូ! មិនមែន ស៊ូ ម៉េត ទេអញ្ចឹង។

អ៊ូ គីមៈ បាទ!

សុខ វណ្ណះ: ប្រធានកងពលធំមាន តាមុត នៅប្រចាំការនៅហ្នឹង?

អ៊ូ គីមៈ បាទ! តាមុត។

សុខ វណ្ណះ: ហើយកងពលនៅហ្នឹង គេមានប៉ុន្មានកងពលនៅខាងកំពង់សោមហ្នឹង?

អ៊ូ គីមៈ កងពលកំពង់សោមហ្នឹង មានតែ១៦៤ហ្នឹងមួយទេ។

សុខ វណ្ណះ: កងពល១៦៤ មួយទេ?

អ៊ូ គីមៈ បាទ! តាសេង, តាមុត តាពីរនាក់ហ្នឹង ប្រធានកងពលហ្នឹង។ ហើយរួចពីហ្នឹងមក គេក៏បញ្ជូនខ្ញុំឲ្យទៅនៅកោះរុង។ ខ្ញុំនៅកោះរុងបានប្រហែល១ឆ្នាំជាង គេបញ្ជូនខ្ញុំឲ្យទៅនៅកោះតាង។ បញ្ជូនខ្ញុំទៅនៅកោះតាង នៅបានមួយរយៈធំ គេក៏បញ្ជូនខ្ញុំទៅនៅកោះពូលូវៃវិញម្តង។ ហើយប្រវត្តិដែលខ្ញុំរស់នៅកោះពូលូវៃហ្នឹង គឺមានការដូចត់ណាស់ សូម្បីតែការហូបចុកក៏មិនដែលបានគ្រប់គ្រាន់ដែរ។ ហើយថ្ងៃឡើងធ្វើការគ្មានម៉ោងពេល ម៉ោងឈប់ទេ វែកខ្សាច់ ធ្វើត្រង់សេ ហើយហ្នឹងហែលទឹក។

សុខ វណ្ណះ: បាទ ពូ! កោះ បើតាមពូនៅ ធ្លាប់នៅ រស់នៅលើកោះហ្នឹងច្រើនឆ្នាំដែរ ពូអាចស្គាល់កោះណាខ្លះទេ? កោះរបស់ខ្មែរយើងនៅខាងកំពង់សោម កំពត ពូអាចរៀបរាប់បានទេកោះ?

អ៊ូ គីមៈ បាទ! រៀបរាប់បាន។ កោះខ្មែរយើងមាន ពូលូវៃចាស់ ពូលូវៃថ្មី កោះព្រីង កោះកុក កោះទន្សាយ កោះរ៉ុង កោះអង្រ្កង កោះសេះ។

សុខ វណ្ណះ: ហ្នឹង! កោះទាំងអស់ហ្នឹងនៅសម័យពាឆ្នាំហ្នឹង គឺអត់មានថៃឬក៏យួន វាមកគ្រប់គ្រងលើកោះទាំងអស់ហ្នឹងបានទេ?

អ៊ូ គីមៈ អត់! អត់! បាទ! ជាការពិតហើយ។

សុខ វណ្ណះ: ខ្មែរយើងទាំងអស់។

អ៊ូ គីមៈ បាទ! ជាការពិតហើយ។

សុខ វណ្ណះ: បាទ! លើកលែងតែកោះត្រល់ទេដែលមានវៀតណាមនៅ។

អ៊ូ គីមៈ បាទ!

សុខ វណ្ណះ: បាទ! អញ្ចឹងកាលកោះត្រល់ហ្នឹង យើងព្យាយាមវ៉ៃដែរ នៅឆ្នាំ៧៥ហ្នឹង ប៉ុន្តែយើងវ៉ៃយ៉ាងមេ៉ច ពូកាលហ្នឹង?

អ៊ូ គីមៈ ក្រោយពីយើងបានទៅនៅ កោះពូលូវៃហ្នឹង ហើយពេលរំដោះហើយហ្នឹងយើងបានឡើង ទៅកោះត្រល់ហ្នឹងមួយឈុលដែរ។ កងពល តាសារឿន នេះ បានឡើងទៅមួយឈុលដែរ ទៅលើកោះត្រល់ហ្នឹង ជាគោលការណ៍ យើងទៅយកទឹកដីរបស់យើងវិញ ក៏ប៉ុន្តែជាកម្មអកុសលអី យើងអត់ទាន់បានយកទេ ដោយសារកម្លាំងយើងតិចតួចអញ្ចឹង ដូច្នេះយើងធ្វើមិនកើត។ ហើយកោះនេះទៀត មានប្រវត្តិខ្មែរនៅហ្នឹងតាំងពីដើម ពិតមែនតែយួនវាចេះតែបញ្ចូលចូលៗ តែខ្មែរយើងមានតាំងពីដើមមក។ រហូតមកដល់សព្វថ្ងៃនេះ ប្រហែលជាអាចអស់ខ្មែរ ក៏ខ្ញុំមិនហ៊ាននិយាយព្រោះខ្ញុំមិនដែលបានទៅ ប៉ុន្តែ ពីមុនមកខ្ញុំដឹងថាមានខ្មែរនៅហ្នឹង។

សុខ វណ្ណៈ កាលហ្នឹង ពូអត់បានចូលរួមប្រយុទ្ធវៃកោះត្រល់ទេ?

អ៊ូ គីមៈ បាទ! អត់បានទេ ព្រោះកងពលខុសគ្នា។ មានលោក សារឿន នេះ សារឿន៦២ នេះគាត់ឡើងនាំទ័ពទៅ។

សុខ វណ្ណៈ បើតាមពូដឹង ប្រហែលជាកាលហ្នឹងគេរៀបចំកម្លាំងយ៉ាងម៉េច? ហើយគេចាប់បានយ៉ាងម៉េច? មុនហ្នឹងពូដឹងដែរថាគេចាប់ហើយគេបញ្ជូនមកវិញយ៉ាងម៉េច?

អ៊ូ គីមៈ ហ្នឹងដំបូងយើងរំដោះហើយ ដំបូងហ្នឹង កម្លាំងមួយចំនួនឲ្យទៅប្រចាំការនៅកោះពូលូវៃហ្នឹង ដល់ទៅនៅប្រចាំការអញ្ចឹង យួននេះវាមកវៃយកហើយ គេមកចាប់ទាហានខ្មែរយើងដែលនៅលើកោះពូលូវៃ កោះដីយើង គេចាប់យកទៅកោះត្រល់ហ្នឹង។ ហើយដល់ក្រោយមកមានការចរចារគ្នាជាមួយថ្នាក់ដឹកនាំយើងហ្នឹង ក៏គេលែងទាហានខ្មែរដែលគេចាប់នៅលើកោះត្រល់ឲ្យមកវិញ។ រួចហើយបានខ្ញុំនេះបានឡើងទៅក្រោយទៅនៅឈរជើងនៅកោះពូលូវៃថ្មីហ្នឹង។

សុខ វណ្ណៈ បាទ! ចុះពូ ទាហានដែល ទាហានវៀតណាមចាប់ទាហានខាងខ្មែរក្រហម ប្រហែលជាប៉ុន្មានរយនាក់ដែរពូ តាមពូដឹង?

អ៊ូ គីមៈ បើតាមខ្ញុំដឹង តាមមិត្តភ័ក្រខ្ញុំនិយាយថាកាលហ្នឹង ៦០០នាក់។

សុខ វណ្ណៈ ចាប់បានទាំងអស់ ឬក៏ម៉េច?

អ៊ូ គីមៈ បាទ! ចាប់បានទាំងអស់។

សុខ វណ្ណៈ កាលហ្នឹង យើងទៅវៃយកកោះត្រល់ តើយើងមានដូចជាសម្ភារៈ មានអាវុធ មានកប៉ាល់ មានទូក មានអីទៅ? ឬក៏យើងទៅដោយរបៀបម៉េច?

អ៊ូ គីមៈ តាមពិតទៅ កាលទៅកោះត្រល់ ខ្ញុំអត់បានឡើងទៅទេ ក៏ប៉ុន្តែមិត្តភ័ក្រគេផ្តល់ព័ត៌មានមកថា យើងបានឡើងទៅលើកោះត្រល់ មានកប៉ាល់ មានអាវុធដែរ។ មិនអត់ទេ!

កំប៉ុន្តែដល់ក្រោយមកទៀត ប្រហែលជាដំណើរការហ្នឹងមិនកើត យើងក៏ដូចដកចេញមក ។

សុខ វណ្ណៈ: ខ្ញុំចង់ឲ្យពូរៀបរាប់ទាហានទាំងអស់ តើនៅលើកោះ តើយើងនៅលើកោះហ្នឹង យើងនៅការពារកោះ ឬក៏យើងនៅធ្វើអីនៅកន្លែងកោះដែលពូនៅហ្នឹង?

អ៊ូ គីមៈ តាមពិតយើងនៅលើកោះហ្នឹង យើងនៅការពារកោះ យើងអត់មានធ្វើអីទេ អត់មានប្រកបមុខរបរធ្វើស្រែធ្វើអីទេ ។ គឺមានតួនាទីមួយ គឺគ្រាន់តែការពារកោះហ្នឹង ។ ហើយដាំដំណាំតិចតួច រួមផ្សំតិចតួចហ្នឹង មិនមានធ្វើអីទេ ។ ហើយទាហានជំនាន់នោះគឺពេញ ឧទាហរណ៍ថា មួយកងធំគឺពេញៗ អត់មានកន្លះដូចសព្វថ្ងៃទេ ។

សុខ វណ្ណៈ: បាទ! ហើយយើងនៅលើកោះ តើមានជួបព្រឹត្តិការណ៍អីខ្លះពូ? ដូចកាលហ្នឹងមានដូចថា ទូកថៃនេសាទ ទូកយួន មានទូកនេសាទ មានអ្នករត់ អ្នកអី ។ អាហ្នឹងយើងធ្វើចំណាត់ការយ៉ាងម៉េចដែរ នៅពេលហ្នឹងពូ?

អ៊ូ គីមៈ តាមពិតទៅយើងនៅលើកោះហ្នឹង យើងបានឃើញព្រឹត្តិការណ៍មួយ ជនជាតិវៀតណាមដែលវារត់ចេញពីប្រទេសរបស់ខ្លួន ហើយទៅជ្រកកោននៅប្រទេសជិតខាង ក៏ឃើញមានដែរ ។ ក៏ឃើញមានដែរ មិនត្រឹមតែប៉ុណ្ណឹង ប្រទេសថៃបានចូលទៅចាប់ត្រីកម្ពុជា ក៏យើងបានឃើញដែរ ។ ហើយយើងក៏បានអន្តរគមន៍ដែរបញ្ហានេះ ទាំងយួនទាំងថៃ ។

សុខ វណ្ណៈ: យើងចាប់បានដែរ?

អ៊ូ គីមៈ បាទ! ចាប់បានដែរ ។

សុខ វណ្ណៈ: ចុះពូ ពូថាយួនដែលឆ្លងកាត់មកយើងចាប់បាន ដូចថាមានទ្រព្យសម្បត្តិ យើងត្រូវរឹបអូសយកដែរ ឬក៏យ៉ាងម៉េច?

អ៊ូ គីមៈ បាទ! អាពីរឿងទ្រព្យសម្បត្តិ ឧទាហរណ៍ថា ដូចរបស់មាសពេជ្រគេយកហើយ ។

សុខ វណ្ណៈ: អញ្ចឹង!

អ៊ូ គីមៈ បាទ! គេយកហើយ ។

សុខ វណ្ណៈ: ចុះមនុស្សមួយចំនួនគេបញ្ជូនមកវិញ ឬក៏ខ្លះត្រូវស្លាប់ដែរ?

អ៊ូ គីមៈ មនុស្សមួយចំនួនគេបញ្ជូនមកវិញ តែមួយចំនួនទៀតក៏ត្រូវស្លាប់ដែរ ។

សុខ វណ្ណៈ: គេអត់បញ្ជូនមកភ្នំពេញ ឬក៏គេសម្លាប់នៅកោះហ្នឹងតែម្តង ឬក៏ម៉េច?

អ៊ូ គីមៈ គេបញ្ជូន ទីមួយគេបញ្ជូន គេថាអ្នកឯងទៅវិញទៅដោយបើកទូកធន់តូចឆ្លងកាត់ គ្រោះថ្នាក់ទៅវិញទៅ។ ហើយមួយចំនួនទៀតក៏គេចាត់ទុកថាអ្នកឯងជាខ្មាំង ជាសត្រូវឈ្លានពានទឹកដីរបស់គេ គេក៏សម្លាប់។

សុខ វណ្ណៈ ចុះ! ដូចនៅកន្លែងមេរបស់ពូ កន្លែងកោះពូលូវៃថ្មី?

អ៊ូ គីមៈ បា៉ទ!

សុខ វណ្ណៈ អញ្ចឹង! មេពូ ឈ្មោះអីដែរ?

អ៊ូ គីមៈ ឈ្មោះ ណន។

សុខ វណ្ណៈ ណន! ឥឡូវគាត់នៅទេ ណនហ្នឹង?

អ៊ូ គីមៈ ណនហ្នឹង មិនដឹងជាយ៉ាងម៉េចទេ ខ្ញុំមិនដែលជួបសោះណន។ ប្រធានវរៈហ្នឹង ឈ្មោះណន។

សុខ វណ្ណៈ ប្រធានវរសេនាធំ?

អ៊ូ គីមៈ បា៉ទ! វរសេនាតូច។

សុខ វណ្ណៈ ប៉ុន្មាននាក់មួយវរសេនាតូច? វាមានប៉ុន្មាននាក់?

អ៊ូ គីមៈ វាមានប្រហែលជា៣០០ជាង។

សុខ វណ្ណៈ អ៊ូ! ច្រើនដែរ។

អ៊ូ គីមៈ ប្រហែលជា៤០០ ព្រោះមានកងកាំភ្លើងធំមួយកង ហើយមានអាថ្មើរជើងវាពាកងទាំងអស់មាន៤០០នាក់។

សុខ វណ្ណៈ បា៉ទ!

អ៊ូ គីមៈ ៤០០ពេញ។

សុខ វណ្ណៈ ហើយ កាំភ្លើងទាំងអស់បានមកពីណាដែរ កាំភ្លើងធំ កាំភ្លើងតូច?

អ៊ូ គីមៈ កាំភ្លើងធំ កាំភ្លើងតូចតាមពិត ក្រោយពីការរំដោះហើយ៧៥ យើងបានបញ្ជូនសម្ភារៈអាវុធទៅរៀបចំការពារកោះរបស់យើងនៅកោះពូលូវៃ។ យើងយកពីកំពង់សោម ពីនេះទៅទេ។ ទៅរៀបជាកាំភ្លើងតូច កាំភ្លើងធំនៅកន្លែងកោះហ្នឹងគ្រប់កន្លែងកោះទាំងអស់។

សុខ វណ្ណៈ ចុះពូ! ដូចថា ឧទាហរណ៍ ពេលវៀតណាម ប្តូក៏អីឆ្លងកាត់ហ្នឹងចាប់ពីឆ្នាំ៧៥មក ប្តូក៏ឆ្នាំណាដែលមានមនុស្សរត់ច្រើនជាងគេ? ឆ្លងទូកឆ្លងអីមក។

អ៊ូ គីមៈ ខ្ញុំដឹង តាំងពីខ្ញុំទៅនៅកោះពូលូវៃ ខ្ញុំឃើញរត់រហូត។

សុខ វណ្ណៈ តាំងពី៧៥មក?

អ៊ូ គីមៈ បាទ! ខ្ញុំឃើញរត់រហូត ។

សុខ វណ្ណៈ ហើយកោះដែលពូនៅ គឺវានៅជាប់ ព្រំដែនទឹកអន្តរជាតិអញ្ចឹងហ្នឹង?

អ៊ូ គីមៈ បាទ! ហ្នឹងហើយ! នៅខ្សែទឹកអន្តរជាតិ ។ ហើយយួនដែលវាមកនៅនេះ យួនដែលវារត់នេះ ទូកវាតូចៗ ។

សុខ វណ្ណៈ មានស្រី មានប្រុស?

អ៊ូ គីមៈ បាទ! មានកូន អាយ៉ោគអាយ៉ាគ រញ៉េរញ៉ៃ ពេញលើទូក ។ ហើយទូកវាតូចៗ មិនគួរវាហ៊ានឆ្លង ប្រថុយគ្រោះថ្នាក់ដល់ថ្នាក់នេះទេ ។

សុខ វណ្ណៈ អញ្ចឹង! ដូចទាហាន ស្រីៗដល់ពេលឃើញស្អាតៗ យើងមានចាប់ទេ?

អ៊ូ គីមៈ អត់!

សុខ វណ្ណៈ យើងមានចាប់ទេ? ចាប់រំលោភ ចាប់អីទេ?

អ៊ូ គីមៈ អត់! រឿងរំលោភអត់មានទេ ។

សុខ វណ្ណៈ អញ្ចឹង!

អ៊ូ គីមៈ បាទ ។

សុខ វណ្ណៈ អត់មានអ្នកណាហ៊ានទេ?

អ៊ូ គីមៈ បាទ! អត់ ធ្វើកបានទេៗ ។

សុខ វណ្ណៈ ខ្លាចអង្គការថ្នាក់លើដែរ ឬក៏យ៉ាងម៉េច?

អ៊ូ គីមៈ បាទ ខ្លាច! ទី១ សីលធម៌ស្អាតស្អំ ។ ទី២ អត់មានយ៉ោយ៉ាអញ្ចឹងបានទេ ។ វិន័យ គឺវិន័យ ។ បើកាលដឹងតែតិច ចប់ហើយ ចប់ជាស្ថាពរតែម្តង មិនចាំបាច់ថានេះ គឺវាចាត់ការភ្លាម ។

សុខ វណ្ណៈ ចុះពូ នៅហ្នឹង ដូចថា ថៃ ពួងឯង កាលហ្នឹង មានចាប់បានច្រើនទេ?

អ៊ូ គីមៈ បានៗថៃ ពីព្រោះថៃដែលវាចូលទៅអូសត្រី វាចូលទៅរកត្រីនៅសមុទ្រខ្មែរយើង ។ យើងបានអន្តរគមន៍យើងចាប់យកមកដែរ ។ មួយចំនួនក៏យើងបានលែងលែងឲ្យទៅវិញ ។ មួយចំនួនទៀតក៏យើង ខ្ញុំឃើញថាមានការស្លាប់នៅកន្លែងដែរ ។

សុខ វណ្ណៈ ម៉េចបានស្លាប់? យើង ដូចថាយើងចាត់ទុកថាអ្នកហ្នឹងខ្លាំង ។ យើងសម្លាប់ចោល បាញ់សម្លាប់ចោល ឬក៏ម៉េច?

អ៊ូ គីមៈ ទេ! អត់បានគិតថាអញ្ចឹងទេ អូន ។ គេគិតថាអ្នកឯងចូលមកយកត្រី យកអីទៅប្រទេសគេ គេអត់មានគិតថាអ្នកឯងខ្លាំង មិនខ្លាំងអីទេ ។ អ្នកឯងខុសហើយ ត្រូវតែនេះ ។

ឡុង ដានី: សម្លាប់ហើយ ។

អ៊ូ គីម: ប៉ា៎ទ!

សុខ វណ្ណះ: អត់បានសួរថ្នាក់លើ ថ្នាក់អីសិនទេ កាលហ្នឹង?

អ៊ូ គីម: ថ្នាក់លើហ្នឹង គេបញ្ជាតាមប្រព័ន្ធបណ្តាញរបស់គេ ។ គេត្រូវតែអញ្ចឹង ។

សុខ វណ្ណះ: យើងទាក់ទងមកលើដែរ? ពេលចាប់បានយើងទាក់ទងទៅលើ ។

អ៊ូ គីម: ប៉ា៎ទ!

សុខ វណ្ណះ: ថ្នាក់លើបញ្ជាមក យើងធ្វើតាមថ្នាក់លើបញ្ជា ។

អ៊ូ គីម: ប៉ា៎ទ! វាពាក់ព័ន្ធអញ្ចឹង អូន ។ ប៉ុន្តែចំពោះពួកអាក្រោមៗ ដូចថាអាកូនទាហាន វាអត់ដឹងអីទេ ។ ឲ្យតែគេបញ្ជាមក គេចង្អុលឲ្យធ្វើម៉េច គឺធ្វើអញ្ចឹងហើយ ។ ហើយគ្មានអាណាហ៊ានប្រកែក ។ បើអ្នកឯងហ៊ានប្រកែក អានោះគេនិងដាក់អ្នកឯងទៀតឥឡូវ ។ វាអញ្ចឹង បានថាពិបាកណាស់ ។

សុខ វណ្ណះ: ចុះ អាហារ របបហូបចុកមិនអីទេ?

អ៊ូ គីម: មិនជាការគ្រប់ទេអូន ។ សព្វថ្ងៃ ខ្ញុំនៅកោះហ្នឹងទម្រាំដល់បានខ្ញុំចេញមក ពេលខ្លះខ្ញុំអត់ពេក ខ្ញុំបេះផ្លែត្រប់ ត្រប់ក្តួរគោ ហើយខ្ញុំបុកអំបិលម្ទេស ។ ខ្ញុំប្រលក់ស៊ីជាមួយក៏មានដែរ ហើយហ្នឹងគល់ស្លឹកគ្រៃ ។

សុខ វណ្ណះ: អ៊ូ! យើងដាំបានដែរ?

អ៊ូ គីម: ប៉ា៎ទ! មុនដំបូង យើងដាំបន្លែបាន ។ នេះជាការពិត ។ នេះមិនមែននិយាយប្រឌិតឲ្យនេះទេ ។ ហើយបាយមិនគ្រប់គ្រាន់ទេអូន ។ កាលហ្នឹង យើងលាយដំឡូង ។ ដំឡូងមីហ្នឹង យើងលាយ ។ ក្រោយមក បានយើងផលិត ដំឡូងដូចបានច្រើនបានគ្រប់គ្រាន់ ។ ពីមុនបាយតិចៗទេ ហើយធ្វើការផង ហូបមិនគ្រប់ ។ គ្រប់យើង គ្រប់ស្រួយ ។ យើងបុកអំបិលលួចទៅស៊ីនៅតាមចំការនោះទៀត ។ ហើយគល់ស្លឹកគ្រៃ គល់ស្លឹកគ្រៃខ្ចីៗហ្នឹង ។

សុខ វណ្ណះ: ចុះបើត្រីវិញសម្បូរដែរ?

អ៊ូ គីម: ត្រីសម្បូរ ។

សុខ វណ្ណះ: តែយើង ......

អ៊ូ គីម: តែសម្បូរហ្នឹង ដោយសារតែអញ្ចេះទេអូន ត្រីសម្បូរហ្នឹង គឺគ្មានឧករណ៍ធ្វើវាបានទេ ។ បើនិយាយពីស្តួចតិចតួច យើងមិនអាចឧបត្ថមមនុស្សរាប់រយបានទេ ។ អញ្ចឹង! ដល់តែយើងត្រូវការចាប់ពីថៃ ថៃទូកវាធំៗហ្នឹង យើងចាប់មក ។

សុខ វណ្ណះ៖ យើងមានមង យើងមានយកមកហើយ?

អ៊ូ គីម៖ អត់ទេ! ត្រីពេញគុក ។ ត្រីធ្មើកន្ទះខែបានអស់ត្រី ។

សុខ វណ្ណះ៖ អ៊ូ!

អ៊ូ គីម៖ ត្រីសម្បើមណាស់ ។

សុខ វណ្ណះ៖ អញ្ចឹង! មនុស្សដល់៣០០នាក់ អត់មានអ្នកខាងកងនេសាទ កងអីសម្រាប់ផ្គត់ផ្គង់ទេអញ្ចឹង?

អ៊ូ គីម៖ អត់មានទេ!

សុខ វណ្ណះ៖ អញ្ចឹង!

អ៊ូ គីម៖ អត់មានទេ!

សុខ វណ្ណះ៖ អញ្ចឹង! ពូនៅហ្នឹងវាមានរឿងរ៉ាវច្រើន ដូចជាក្រៅពីទូកនេសាទថៃ ក្រៅពីអ្នករត់ឆ្លងដែនពីវៀតណាម ។ នៅហ្នឹងលឺថាមានចាប់ កប៉ាល់ម៉ាយ៉ាហ្គេស ពូដឹងរឿងហ្នឹងទេ?

អ៊ូ គីម៖ បាទ ដឹង! ដឹងរឿង ។ ចំណុចហ្នឹងខ្ញុំដឹងរឿង ។ កាលហ្នឹង វាទម្លាក់ អើ! កាលហ្នឹងចាប់កប៉ាល់ម៉ាយ៉ាហ្គេសរបស់អាមេរិចកាំង ។ ពេលហ្នឹង ខៀវ សំផន បានប្រកាសថាកប៉ាល់អាមេរិចកាំងបានរំលោភចូលបូរណភាពទឹកដីកម្ពុជា ។ ដូច្នេះ ខៀវ សំផន ក៏គាត់បញ្ជាឲ្យនាំកប៉ាល់ហ្នឹងចូលទៅកំពង់សោម គ្រាន់តែបញ្ជាកប៉ាល់ហ្នឹងមិនទាន់ដល់កំពង់សោមផង យន្តហោះអាមេរិចកាំងក៏ចាប់ផ្ដើមធ្វើអន្តរាគមន៍ព្រឹកភ្លាម ។ ក្នុងហ្នឹងទម្លាក់កងគេង ហើយនឹងទម្លាក់លើកោះតាង ហើយនឹងមានទាហានអាមេរិចកាំងមួយចំនួនដែលហោះមកលើកោះ តាងហើយមានការប្រយុទ្ធគ្នា បាញ់យន្តហោះធ្លាក់មួយ ។ ហើយស្លាប់នៅលើកោះតាងទៀតផង ។

សុខ វណ្ណះ៖ ចុះហេតុអ្វីបានពូដឹងថា ខៀវ សំផន គាត់អ្នកបញ្ជាឲ្យចាប់អញ្ចឹង? ពូឯងដឹងតាមពីណាគេ?

អ៊ូ គីម៖ ព្រោះកាលហ្នឹងគណៈប្រធានរដ្ឋគឺ ខៀវ សំផន ។

សុខ វណ្ណះ៖ អញ្ចឹង!

អ៊ូ គីម៖ ហើយខ្ញុំស្ដាប់បានខៀវ សំផនគាត់ប្រកាសតាមវិទ្យុ ថាកប៉ាល់អាមេរិចកាំងបានរំលោភចូលទឹកដីប្រទេសកម្ពុជា ។ ខ្ញុំបានស្ដាប់លឺគាត់និយាយអញ្ចឹង ។

សុខ វណ្ណះ៖ បាទ! នៅឆ្នាំណា? កប៉ាល់ហ្នឹង?

អ៊ូ គីម៖ ឆ្នាំហ្នឹង ខ្ញុំដូចជាភ្លេចឆ្នាំទៅហើយ ។

សុខ វណ្ណះ៖ បែកភ្លាមៗ ឬក៏ម៉េច?

អ៊ូ គីម: បែកយូរដែរហើយ មិនជាភ្លាមប៉ុន្មានទេ។ ដូច៧៦ទេដឹង! ចំណុចហ្នឹងខ្ញុំអត់ច្បាស់ទេ។

សុខ វណ្ណះ: ក្រោយមកលឺថា យើងលែងទៅវិញបានមានបញ្ហាហ្នឹង?

អ៊ូ គីម: បា៎ទ! ក្រោយមកក៏លែងទៅវិញ។ ដល់លែងទៅវិញ កប៉ាល់ទម្លាក់រាមខ្ទិចខ្ទីអស់ អាលីញ ហើយមិនទម្លាក់ត្រឹមរាមទេ ទៅទម្លាក់អីណាណោះទៀត។ ហ្នឹងរបស់អាមេរិចកាំង។

សុខ វណ្ណះ: នេះចាប់ចំកប៉ាល់អាមេរិចកាំង។ បើចាំចាប់ចំកប៉ាល់យួន យើងនៅធ្វើស៊ីបាន។ មិនខ្លាចអំណាច។ ដល់ពេលចាប់អាមេរិចកាំង យើងខ្លាចវាដែរ។ ខ្មែរក្រហមខ្លាចដែរ។

អ៊ូ គីម: កប៉ាល់អាមេរិចកាំងវាធំណាស់។ ហើយពេលដែលយើងទៅ យើងអត់បានចាប់ទូរលេខគេបានទេ។ មិនដឹងទូរលេខគេនៅបន្ទប់ណាទេ ដូច្នេះគេទាក់ទងទៅអាមេរិចហើយ បាត់ហើយ។ ហើយយើងទៅដល់ គេបោះខ្សែពួរឲ្យឡើងទៀត។ គេបោះខ្សែពួរឲ្យយើងឡើង ហើយគេដាក់

សុខ វណ្ណះ: ឡើងឆែកចុ៎ះ!

អ៊ូ គីម: បា៎ទ! ហើយបារីគេក្នុងមួយកញ្ចប់មានតែ២ដើម តែវែង មួយចង្អាម។ ហើយនំកំប៉ុងឲ្យយើងកោស។ ចានគេហូបហើយគេទម្លាក់ចោលប្រាវ។ គេអត់លាងទុកដូចយើងទេ។ គ្រាន់តែនាំកប៉ាល់ចូលទៅកំពង់សោម យន្តហោះគេមកព្រឹបភ្លាម។

សុខ វណ្ណះ: កប៉ាល់ហ្នឹងធំ?

អ៊ូ គីម: ធំ! បាទ ធំ។

សុខ វណ្ណះ: ហើយនៅក្នុងមានទំនិញស្អីខ្លះទៅ?

អ៊ូ គីម: យើងអត់បានឆែកបន្ទប់គេបានទេ ពីព្រោះយើងគ្រាន់តែដឹង សូម្បីតែទូរលេខគេ យើងចាប់អត់បានផង។ ទូរលេខនៅបន្ទប់ណាបន្ទប់ណី យើងអត់ដឹង។ គ្រាន់តែគេឲ្យម្ចាស់គេ គេបោះអាខ្សែពួរឲ្យយើងឡើងទៅលើរបស់គេ។ យើងអត់ដឹងទេ។

សុខ វណ្ណះ: ហើយយើងអត់ចាប់ម្ចាស់ហ្នឹងទេ?

អ៊ូ គីម: ម្ចាស់មួយចំនួនគេឲ្យយើងឃើញក្នុងវាលដូចអញ្ចឹងណា តែមួយចំនួនទៀតនៅក្នុងបន្ទប់ថតៗរបស់គេ។ យើងរកគេអត់ឃើញ សម្រាប់ទាក់ទងសម្ងាត់ណា៎។

សុខ វណ្ណះ: បា៎ទ!

អ៊ូ គីម: បា៎ទ!

សុខ វណ្ណះ: ហើយយើងអត់មានរករឿងគេប្រទើងប្រទាំងឲ្យគេឡើងមកទេ?

អ៊ូ គីម: អត់ទេ! អត់បានទេ! ព្រោះអានេះ វាអាមេរិចកាំង វាមិនដូចពួកបរទេសផ្សេងៗទេ។

សុខ វណ្ណៈ: យើងខ្លាចអំណាចវាដែរ?

អ៊ូ គីម: វាខ្លាចដែរបង។

សុខ វណ្ណៈ: អញ្ចឹង! ក្រៅពីហ្នឹង លឺថាមាន បរទេស គេចាប់បានតាមទូក តាមអីៗ មានបរទេសគេចាប់បានៗ ពូមានដឹងទេពូ? ជនជាតិបរទេស ទេសចរណ៍ទេស?

អ៊ូ គីម: អត់! អត់ទេ! ខ្ញុំ បញ្ហាហ្នឹងខ្ញុំអត់បានដឹងទេ។ ខុសពីទូកនេសាទថៃ ខុសពីយួនខ្ញុំអត់ដឹងទេ។ បើរឿងបរទេសហ្នឹង ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ដែលឃើញ។

សុខ វណ្ណៈ: ចុះពូនៅលើកោះហ្នឹងនៅរហូតដល់បែក៧៩ ឬក៏ម៉េច?

អ៊ូ គីម: ខ្ញុំនៅរហូតដល់៧៩ ខ្ញុំអត់ដឹងថាសភាពការ៧៩ មានយួនចូល ស្រុកអញ្ចឹងទេ អត់ដឹងទេ ទាល់តែយប់ប្រហែលជាម៉ោង១ គេឲ្យខ្ញុំរៀបចំៗ ខ្ញុំថារៀបចំស្អីគេ ព្រោះខ្ញុំអត់ដឹង។ រៀបចំអញ្ចឹងមក ចាប់មាន់ ចាប់ទាអី អញ្ចឹងមកៗ គេលាក់ស្អីៗ ហើយអាកាំភ្លើងធំមួយចំនួន គឺត្រូវបំផ្លាញចោលមុនពេលគេចេញ តែប៉ុណ្ណឹង។

សុខ វណ្ណៈ: គេបំផ្លាញដើម្បីអីពូ?

អ៊ូ គីម: បំផ្លាញកុំឲ្យ ខ្មាំងសត្រូវ ដូចយួនមកយកកាំភ្លើងប្រើប្រាស់បានទៀតទៅថ្ងៃមុខ។

សុខ វណ្ណៈ: អូ៎!

អ៊ូ គីម: បាទ!

សុខ វណ្ណៈ: ហើយពូ ពេលពូនៅកោះហ្នឹង ដូចថា មាស មុត អីដែលចុះទៅសួរសុខទុក្ខដែរអត់ទេ?

អ៊ូ គីម: អូ៎! ទៅញឹកណាស់ៗ ពេលខ្លះគាត់យកកុន កុនអារឿងទស្សនៈកិច្ចរបស់ប៉ុល ពត ទៅចាក់ឲ្យមើល ហើយគាត់ចែកសណ្តែកដីហ្នឹងម្នាក់មួយកាឲ្យមើលរឿង ប៉ុល ពត ទស្សនៈកិច្ចនៅចិនហ្នឹង។

សុខ វណ្ណៈ: ហើយគាត់មានប្រជុំ ចុះទៅប្រជុំប្រាប់ទាហានអីហ្នឹងឲ្យការពារម៉េច អីយ៉ាងម៉េច? គាត់មានប្រជុំប្រាប់ទេកាលហ្នឹង?

អ៊ូ គីម: បាទ! បញ្ហាហ្នឹង មានអូនៗ បញ្ហាឲ្យយើងការពារបូរាណភាពទឹកដី កុំឲ្យខ្មាំងឈ្លានពានៗ តាមពិត យើងដឹងហើយថាខ្មាំងដែលឈ្លានពានមានអ្នកណា គឺមានតែយួនហ្នឹងឯង អីចឹងគាត់ប្រាប់ដែរបញ្ហា។

សុខ វណ្ណៈ: ពូស្គាល់គាត់ច្បាស់ទេ?

អ៊ូ គីមៈ ស្គាល់ច្បាស់! តាយាង, តាមុត ហ្នឹងច្បាស់ ។

សុខ វណ្ណៈ គាត់ ពូមើលទៅគាត់ តើគាត់ជាមនុស្សកាច ឬក៏ជាមនុស្សធម្មតាមិនកាចមិនអីទេ បើពូមើលចិត្តគាត់ មើលទៅគាត់?

អ៊ូ គីមៈ តាមពិត ខ្ញុំមើល តាយាង ហើយ បងមុត ហ្នឹងមិនមែនជាមនុស្សកាចទេ ។ អត់មែនជាមនុស្សកាចទេ ប៉ុន្តែបើកាច កាចនេះទៅវិញ កាច តាណាន ខ្លាំងវិញ ។ តាណាន ខ្លាំងហ្នឹងដឹងកាចហ្នុង ។ ប្រធានវរហ្នឹងកាច ។

សុខ វណ្ណៈ អញ្ចឹង!

អ៊ូ គីមៈ បាទ! បើបងមុត ហើយខ្ញុំបាននិយាយឈ្មោះទាំង២ខាងលើហ្នឹងគឺមិនកាចទេ ។ មនុស្សមើលរាងមើសៗម៉ក់ៗ ។

សុខ វណ្ណៈ ចុះពូ ដូចថានៅកន្លែងពូយាមហ្នឹង ៣០០-៤០០នាក់ហ្នឹង តើអ្នកទាំងអស់ចេញពីកងពលតែមួយឬក៏មានកងពលផ្សេងមកពីភូមិភាគផ្សេង មានបូព៌ាលាយឧត្តរលាយបស្ចិម អី លាយអញ្ចឹងដែលចំរុះ ឬក៏យ៉ាងម៉េចពូ?

អ៊ូ គីមៈ អត់ទេ! តាមពិតតែមួយកងពលទេអូន តែ១៦៤នេះឯង ។ ដកទៅការពារកោះហ្នឹង តែ១៦៤នេះ អត់មានពីភូមិភាគណាមក ពីណាពីណីទេ អត់មានទេ ។

សុខ វណ្ណៈ អញ្ចឹងសុទ្ធតែខាងភាគច្រើនអ្នកនៅនិរតី?

អ៊ូ គីមៈ បាទ! និរតី ។

សុខ វណ្ណៈ អត់មានខាងបូព៌ាអី គេទៅ ។ ទាហានបូព៌ាទៅហ្នឹងដែរទេ?

អ៊ូ គីមៈ បា! អត់ទេ ។

សុខ វណ្ណៈ ចុះពូ ដូចថាកាលហ្នឹង នៅលើកោះហ្នឹង មានអ្នកណាខុស ត្រូវគេយកទៅសម្លាប់ដែរ ឬក៏បាត់ខ្លួនអីមានទេ?

អ៊ូ គីមៈ អូ! បញ្ហានេះអត់បានទេ ។ សូម្បីតែទៅលួចខេអា ឬក៏លួចដកដំឡូង ដែលអាដំឡូងធម្មតាយើងដាំទាំងអស់គ្នាអញ្ចឹង ពេលដែលមានចិកទៅ វាដាច់អាទងវាចេញពីដើម ហើយយើងទៅលួចដកយកមកដុត គេចោទថាយើងខ្មាំងទៀត ។

សុខ វណ្ណៈ អញ្ចឹង!

អ៊ូ គីមៈ ហើយគេនិងផ្ញើបាប ។ ថ្ងៃមួយហ្នឹងខ្ញុំឃើញអាមួយពួកម៉ាកខ្ញុំ គ្នាខ្ញុំហ្នឹងគេវៃសន្លប់លើព្រលានយន្តហោះកោះពូលូវៃថ្មីហ្នឹង បែកឈាមខ្ទាយ ។

សុខ វណ្ណៈ គាត់ខុសអី?

អ៊ូ គីមៈ រឿងពេលហ្នឹងប្រហែលជារឿងលួចខេអាវគ្នា ។

សុខ វណ្ណះ៖ បាទ!

អ៊ូ គីមៈ រឿងខោអាវតិចតួច ៗ ហើយអត់ នៅកោះពូលូវៃហ្នឹង អត់មានស្រីទេ ៗ

សុខ វណ្ណះ៖ ពីណាអ្នកវៃ? ប្រធានវរឬក៏យ៉ាងម៉េច?

អ៊ូ គីមៈ ហ្នឹងប្រធានកងធំគេ ៗ

សុខ វណ្ណះ៖ បាទ! ហើយកាលហ្នឹង មានតែប្រុសសុទ្ធ ឬក៏ស្រីដែរ?

អ៊ូ គីមៈ អត់មានទេអូន មានតែប្រុសសុទ្ធ សុទ្ធទាំងអស់ហ្នឹង សុទ្ធគ្មានមានលាយលំគ្នា សុទ្ធហ្នឹង ៗ

សុខ វណ្ណះ៖ កាលហ្នឹង ពូអាយុប៉ុន្មានដែរហើយ?

អ៊ូ គីមៈ ប្រហែលជា ១៨ ៗ

សុខ វណ្ណះ៖ អញ្ចឹង!

អ៊ូ គីមៈ បាទ!

សុខ វណ្ណះ៖ អត់មាននឹកនាប្រពន្ធ នឹកនាអី ទេកាលហ្នឹង?

អ៊ូ គីមៈ អត់ទេ អត់ទេ ៗ

សុខ វណ្ណះ៖ ចុះបើយើងចង់បាន យើងប្រាប់មេ?

អ៊ូ គីមៈ អត់ទេ បើយើងចង់បានក៏អត់ន័យដែរ គេអង្គការគេកំណត់ស្រេចៗហើយ ៗ ស្រេចតែគេរៀបចំ យើងមានសិទ្ធិអីទៅចង់បានអញ្ចឹងៗ ៗ

សុខ វណ្ណះ៖ ចុះពូ ដូចថា ពូឯងនៅក្នុងហ្នឹងដែលគ្នាយើងនៅ៣០០-៤០០នាក់នេះ ហើយមានពីណាទៅដឹងបើយើងធ្វើខុសបន្តិចបន្តួចអី ៗ យើងគួរអនុគ្រោះឲ្យគ្នា ដូចថាលួចរបស់អីបន្តិចបន្តួចស៊ីចុកអីហ្នឹង ក៏មានវិន័យតឹងដែរ? ដូចថាយើងនៅលើ កោះដាច់ឆ្ងាយ ដូចថាបើប្រជាជននៅភូមិឃុំនេះ នៅតាមស្រុកស្រែចំការ ហ្នឹងគាត់ធ្វើខុសអី ឬក៏មានអីគេស៊ើប ហើយគេយកវៃចោល ដូចថាគ្នាតែពួកពូសោះ ក៏មានដូចបញ្ហាស្លាប់រស់ហ្នឹងដែរ? ម៉េចទៅ?

អ៊ូ គីមៈ អត់មានទេ ៗ អត់មានអ្នកណាដឹងរឿងនេះទេអូន ៗ បើកាលណា បុគ្គលណាមួយធ្វើខុសពីបទ បទបញ្ជារបស់គេឬខុសអីផ្សេងៗគឺមិនអាច មិនអាចដឹងទេ មិនអាចដឹងព័ត៌មាន ៗ

ឡុង ដានីៈ ហើយ កង ដូចថានៅក្នុងកងវរៈហ្នឹងអត់មានផ្លាស់ប្តូរទៅណាទេ?

អ៊ូ គីមៈ បាទ! អត់ទេ! អត់ផ្លាស់ប្តូរទេ ៗ

ឡុង ដានីៈ មកឈរជើងហ្នឹង ៗ ឈរ.......

អ៊ូ គីមៈ បាទ! ហ្នឹងហើយ

ឡុង ដានីៈ ដូចថាពីនិយាយចូលទៅឈរជើងហ្នឹង ពីឆ្នាំប៉ុន្មានទៅលោកពូ?

អ៊ូ គីមៈ រំដោះហើយ៧៥មក ។

ឡុង ដានីៈ ៧៥ ហើយ នៅហ្នឹងរហូតដល់៧៩បណ្ដោយ?

អ៊ូ គីមៈ បាទ! ៧៩ហ្នឹង ។

ឡុង ដានីៈ អត់មាន! សមាសភាពប៉ុន្មាននៅប៉ុណ្ណឹង?

អ៊ូ គីមៈ បាទ! អត់ប្ដូរទេ

ឡុង ដានីៈ ហើយមានដែលបានវៃជាមួយគេពេលនៅលើកោះ?

អ៊ូ គីមៈ តាំងពីខ្ញុំទៅ អត់ទេ ។ អត់ដែលបានវៃអីទេ ។ វៃតែពួកមុន ។ មុនហ្នឹងខ្ញុំទៅឈរជើងហ្នឹង គេវៃគ្នា ។ ហើយដល់ពេលខ្ញុំ ពួកខ្ញុំទៅអត់បានវៃអីទៀតទេ ។

ឡុង ដានីៈ ចុះ ពួកលោកពូទៅអត់ ដែលបានវៃជាមួយនរណា?

អ៊ូ គីមៈ បាទ! អត់ទេ

ឡុង ដានីៈ ចុះគ្រាប់កាំភ្លើង គ្រាប់អី គេយកទៅធ្វើអី បើ.....?

អ៊ូ គីមៈ គេយកទៅដាក់សត្រៀមបម្រុងការពារប្រទេសគេ ការពារប្រទេស ការពារជាតិគេ ។ គេទៅគេមានឃ្លាំងមានអី គេជីកក្នុងដីអី គេធ្វើចាក់ប៉េតង់កម្រាស់ប៉ុន្មានៗ សុទ្ធតែថ្មបាយក្រៀមបាយអី ។ គេចាក់របៀបនេះហើយ គេកប់ក្នុងដីទៀត ។ មិនឲ្យយើងដឹងទេ ។

ឡុង ដានីៈ កាំភ្លើងមានប្រភេទអីខ្លះទៅ?

អ៊ូ គីមៈ មាន ៧៦ ១០៥ ៣៧ អា១២,៧ មាន DK៨២ មាន៧៥ មាន មានអា៨១ អាទំនើប ។

ឡុង ដានីៈ អាទំនើបហ្នឹងស្អីគេ?

អ៊ូ គីមៈ អាប៉េ! អាសាសន៍ក្រហម! អាទំនើប ដូចចិនគេឲ្យមកឥឡូវហ្នឹង ។

ឡុង ដានីៈ អើម!

អ៊ូ គីមៈ អា៨៩ហ្នឹង ប៉េ៥០ អា៨៩អាសាសន៍ក្រហម ។

ឡុង ដានីៈ ហើយកាំភ្លើងដៃ?

អ៊ូ គីមៈ កាំភ្លើងដៃមានតែ AKសុទ្ធ ។ គ្មានលាយអ៊ែរកែងអ៊ែរអីទេ ។

ឡុង ដានីៈ ហើយចុះ កប៉ាល់ចម្បាំង មានចម្បាំងប៉ុន្មានប្រភេទ?

អ៊ូ គីមៈ អត់! អត់មានទេអូនៗ កប៉ាល់ចម្បាំងគឺអត់មានទេ លុះត្រាតែយើងត្រូវការ អីចេញចូលអី មានចម្បាំងមានអី បានគេហៅពីកំពង់សោមទៅៗ បើថាឲ្យមានកប៉ាល់ចម្បាំងនៅហ្នឹងគឺអត់មានទេ សូម្បីតែធ្វើដំណើរតាមទូកដឹកទាហានទៅមកហ្នឹង គឺយើងប្រើទូកឈើៗ អត់មានទូកដែកទេៗ ធន់២៥០សេស ធន់៥០០សេស ......

ឡុង ដានីៈ អ៊ូ! ២៥០សេសហ្នឹងជិះបានប៉ុន្មានដែរ?

អ៊ូ គីមៈ ជិះហ្មែ!

ឡុង ដានីៈ បាទ!

អ៊ូ គីមៈ អ៊ូ! ជិះបានច្រើនណាស់អូនៗ សឹងតែរាប់រយហើយៗ ២៥០ហ្នឹងធំៗ

ឡុង ដានីៈ ២៥០សេសហ្នឹង?

អ៊ូ គីមៈ បាទ! ធំណាស់ៗ

ឡុង ដានីៈ បើមួយវរហ្នឹងជិះអស់អត់?

អ៊ូ គីមៈ អើម! អស់ៗ

ឡុង ដានីៈ បាទ!

អ៊ូ គីមៈ អស់ៗ

ឡុង ដានីៈ ៣០០នាក់ហ្នឹងជិះអស់អត់?

អ៊ូ គីមៈ អស់ៗ

ឡុង ដានីៈ តែមួយទេ?

អ៊ូ គីមៈ បាទ! តែមួយៗ តែធំ ទូកធំៗ បើ៥០០ឡើងទៅ ទៅ៨០០ ១០០០ណោះអាហ្នឹង ២វរៈអីៗ

ឡុង ដានីៈ ចុះ! បើពេលទូកគេឆ្លងកាត់ ដូចទូកពួកយួនវារត់ឆ្លងកាត់ យើងចាប់វាម៉េច? យើងយកអីទៅចាប់?

អ៊ូ គីមៈ ថ្នាក់លើ ប្រធានវរៈគេ ប្រធានវរៈ វរសេនាតូចហ្នឹងគេហៅកប៉ាល់ពីកំពង់សោមទៅៗ

ឡុង ដានីៈ ហៅទៅទាន់ដែរ?

អ៊ូ គីមៈ លឿនៗ កប៉ាល់គេលឿន សម្រាប់ចាប់ហ្នឹងៗ ហៅទៅតែមួយម៉ោង ឬកន្លះម៉ោងដល់ហើយៗ និយាយពីដល់កុនអញ្ចឹងទៅ វាមានតែក្បាលទេ អាតួទលិចអស់ហើយៗ វាមានតែក្បាល ទឹកសសំពោង មើលទៅឃើញតែទឹកសសំពោងៗ

ឡុង ដានីៈ ហើយចុះទូក គ្រាន់ទូកពួកប្រជាជនរត់ ភាគច្រើនហៅកប៉ាល់ពីណា ពីកំពង់សោមទៅចាប់ដែរ?

អ៊ូ គីមៈ បាទ! អាហ្នឹងជាគោលការណ៍របស់ខាងលើ ។ គេមិនដឹងចាប់យ៉ាងម៉េចអីយ៉ាងម៉េច យើងក៏មិនដឹងដែរបញ្ហាហ្នឹង ។

ឡុង ដានីៈ ចាំមើល ឧបមាថាទូកហ្នឹងយើងឃើញអញ្ចឹង ហើយកប៉ាល់មួយម៉ោងពីរម៉ោង បានន័យថាទូកហ្នឹងអត់ទាន់ផុតពីហ្នឹង?

អ៊ូ គីមៈ អត់ទាន់ផុតទេ ។ ផុតទៅណារួច បើគេដឹងថាល្បឿនទូក វាយឺត ។ បើល្បឿនទូកតូចវាយឺត ដូចច្នេះកន្លះម៉ោង ក៏មិនផុតដែរ ។ ទូកវាសុទ្ធតែទូកឈើ ។ បើនេះទូកដែកទូកកប៉ាល់ចម្បាំង ។

ឡុង ដានីៈ ដែលចាប់បាន បានយកមកដាក់នៅកោះពូលូវៃ?

អ៊ូ គីមៈ បាទ! ដល់ពេលចាប់បាន បានគេនាំ អ្នកនេះហ្នឹង នាំអាពួកហ្នឹងមកលើនៅកោះពូលូវៃ ។

ឡុង ដានីៈ អញ្ចឹងឲ្យតែចាប់អញ្ចឹង គឺហៅពីកំពង់សោមទៅទាំងអស់?

អ៊ូ គីមៈ បាទ! ហៅពីកំពង់សោមទាំងអស់ ។ គ្មានទូកនេះហ្នឹង អត់មកតាមកោះទេ ។ មានតែពីរាមទៅហ្នឹង ឬក៏ពីស្ទឹងហាវទៅ ។ តែកប៉ាល់ហ្នឹងឥឡូវមិនដឹងយ៉ាងម៉េចហើយអស់ទេ ប្រហែលវាខូចអស់ហើយទៅ ក៏មិនដឹងទេ ។

ឡុង ដានីៈ អាហ្នឹងលឿន?

អ៊ូ គីមៈ លឿន ។

ឡុង ដានីៈ ប៉ុន្មានមួយគីឡូ ប៉ុន្មាន មួយម៉ោងបានប៉ុន្មានគីឡូទៅ?

អ៊ូ គីមៈ អត់ដឹងប៉ុន្មានទេអូន ប៉ុន្តែលឿនហ្នឹង ។

ឡុង ដានីៈ លឿន ។

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ជិះបានប៉ុន្មាននាក់?

អ៊ូ គីមៈ វាចូល៣០នាក់ដែរ ។

ឡុង ដានីៈ មួយកប៉ាល់ហ្នឹង?

អ៊ូ គីមៈ បាទ! មួយកប៉ាល់ហ្នឹង អាលឿនហ្នឹង ។

ឡុង ដានីៈ អើម!! ហើយមានកាំភ្លើង មានគ្រប់ទេ?

អ៊ូ គីមៈ មាន ១២,៧ ហើយនឹង DK៨២ មាននៅលើហ្នឹង ។

ឡុង ដានីៈ ១២,៧ ហើយនឹង DK៨២?

អ៊ូ គីមៈ បាទ!

ឡុង ដានី: ហើយចាប់ទូកនេសាទរបស់ថៃអី ក៏ពួកហ្នឹងមកដែរ?

អ៊ូ គីម: មក! មកទាំងអស់ ។

ឡុង ដានី: កប៉ាល់ហ្នឹងដែរ?

អ៊ូ គីម: ហ្នឹង មានតែហ្នឹងឯង ។

ឡុង ដានី: ហើយយើងនៅលើគោកនេះអត់បានចុះទៅចាប់ទេ?

អ៊ូ គីម: អត់ទេ ។ យើងអត់ដឹងទេ ។ យើងអត់ដឹងទេ ។

ឡុង ដានី: ប៉ុន្តែដល់ពេលគេបញ្ជូនមកលើកោះពូលូវៃ បានយើងមានសិទ្ធិទៅឆែកឆេរ ។

អ៊ូ គីម: ហ្នឹងដោយនេះទៀតអូន ដោយស្រេចគេតម្រូវ ។ ឧទាហរណ៍ថា បុគ្គលឈ្មោះនោះក-ខ ឥឡូវទៅយាម ទៅមើលគេចាប់មនុស្សបានមកអញ្ចឹង ។ តែវាមិនទៀងថាបុគ្គលណា បុគ្គលណាទេ ស្រេចតែគេចាត់ចែង ។

ឡុង ដានី: ស្រេចតែគេចាត់ចែងទេ?

អ៊ូ គីម: បាទ!

ឡុង ដានី: ហើយច្រើន ភាគច្រើនដូចថា អ្នកដែល ដូចថាទូករបស់យួនដែលគេចាប់មកកោះពូលូវៃ ចាប់មកភាគច្រើនចាប់មកឃុំយូរទេ មកយាម?

អ៊ូ គីម: ទេ! ប្រហែលជាតាមខ្ញុំដឹងដូចមិនឃុំយូរទេ ។ យ៉ាងខ្ពស់ណាស់៣ថ្ងៃ ។

ឡុង ដានី: អញ្ចឹង! ៣ថ្ងៃ?

អ៊ូ គីម: បាទ! ៣ថ្ងៃ! គេគ្មានបាយឲ្យស៊ីទេ ។

ឡុង ដានី: បាទ! តែ៣ថ្ងៃទេ បើត្រូវបញ្ជូន បញ្ជូន បើត្រូវសម្លាប់ សម្លាប់ទៅ ។

អ៊ូ គីម: បាទ! បើត្រូវបញ្ជូន បញ្ជូន ។ បើត្រូវមិនបញ្ជូន គេចាត់ការរបៀប យ៉ាងម៉េចគេទៀតទៅ ។

ឡុង ដានី: ហើយគេភាគច្រើន អ្នកដែលគេសម្លាប់ហ្នឹង គេច្រើនតែសម្លាប់ហើយ គេមានកប់ឬក៏គេយ៉ាងម៉េចទៀត?

អ៊ូ គីម: អ្នកខ្លះបានកប់ ។ អ្នកខ្លះមិនបានកប់ទេ ។

ឡុង ដានី: អ្នកខ្លះគេយ៉ាងម៉េចទៅ?

អ៊ូ គីម: បាទ! អ្នកខ្លះគេចោល ។ អ្នកខ្លះនៅខិតៗលើដីអញ្ចឹងទៅ ។ អ្នកកខ្លះទៀតបានកប់បានអី ។

ឡុង ដានី: ចុះបើអ្នក បើយើងនៅកណ្តាលវាល បើយើងនៅលើកោះហ្នឹងមិនធំស្អុយ?

អ៊ូ គីម: អត់ទេ ព្រោះកន្លែងហ្នឹង ហើយកន្លែងនេះគេឆ្ងាយ ។ ឆ្ងាយ ឆ្ងាយពីកន្លែងគេនៅ ។

ឡុង ដានី: ចម្ងាយប្រហែលប៉ុន្មាន?

អ៊ូ គីម: ប្រហែលជាកន្លះគីឡូ ។

ឡុង ដានី: កន្លះគីឡូ?

អ៊ូ គីម: បាទ! វាកន្លែង ឧទាហរណ៍កន្លែងខ្មោចហ្នឹងអញ្ចឹង ហើយវានៅកន្លះគីឡូ ។ ហើយបើសិនមានធំក្លិន ធំអី ស្អុយអី គេនិងបញ្ជាកូនទាហានគេមកឲ្យទៅលុបអានេះ ទៅកប់អញ្ចេះ អញ្ចុះហើយ គេមិនឲ្យនេះ ។

ឡុង ដានី: ចុះលោកពូ ដូចថាទ្រព្យសម្បត្តិមានតម្លៃដែលដូចជាមាសប្រាក់ ខាងគេប្រមូលដាក់មួយដុំ ឬក៏យ៉ាងម៉េច?

អ៊ូ គីម: ហ្នឹង កងវរយគេអ្នកប្រមូល ។

ឡុង ដានី: កងវរយគេអ្នកប្រមូល?

អ៊ូ គីម: បាទ! កងវរយគេអ្នកប្រមូល កងធំគេហ្នឹង ។ ហើយដល់ពេលសភាពការណ៍ច្របូកច្របល់ កងធំហ្នឹង វាបាត់ម្ចាស់ការទៅ ។ វាអត់បានគិតគូរបញ្ហាហ្នឹង វាទម្លាក់ឲ្យអ្នកផ្សេងអ្នកគ្រប់គ្រង ។ បាទ! ដល់នេះកងធំវាលែងចង់បាន វាគិតគូរតែពីទាហានពីអីអញ្ចេះអញ្ចុះទៅ វាទម្លាក់ឲ្យអ្នកក្រោមអ្នកទុក ។

ឡុង ដានី: បាទ!

អ៊ូ គីម: អើម!

ឡុង ដានី: បើតាមពី៧៥មកដល់៧៩ បើតាមរបស់មានតម្លៃដូចជាមាស ប្រមូលបានប្រហែលប៉ុន្មានទៅ គិតជាគីឡូ?

អ៊ូ គីម: មិនក្រោម៥គីឡូ ។

ឡុង ដានី: មិនក្រោម៥គីឡូទេ?

អ៊ូ គីម: បាទ!

ឡុង ដានី: អ៊ូ! គិតអ្នកដែល ដូចថារបស់មានតម្លៃហ្នឹង មកគឺយើងនែកនេរយកអស់?

អ៊ូ គីម: បាទ! ហ្នឹងជាការពិតហើយ គឺគេមិនឲ្យសល់ទេរបស់មានតម្លៃ ។

ឡុង ដានី: លាក់ណាក៏អត់បានដែរ?

អ៊ូ គីម: បាទ! លាក់ណាក៏គេយក ។ បើគេរកឃើញក៏គេយក ។ បើរកមិនឃើញ ក៏គេដឹងថាយើងលាក់ ។ គេលាក់ គេហ្នឹង គេដឹងថាលាក់ហ្នឹង អាហ្នឹងគេរឹតខ្លាំងជាង ហ្នឹងទៀត ។

ឡុង ដានី: គេធ្វើ បានន័យថាគេធ្វើទារុណកម្ម?

អ៊ូ គីម: បាទ! ដល់យើង គេថាយើងមិនស្មោះត្រង់ ។

ឡុង ដានី៖ ស្រីៗភាគច្រើនគេលាក់នៅណាទៅ?

អ៊ូ គីម៖ ភាគច្រើនគេ ស្រីៗហ្នឹងគេលាក់នូវក្នុងប្រដាប់បន្តពូជគេ ។ ពីមុខគេបិទជាការ៉ៈ ឬក៏បង់ស្អិត ។ គេបិទនៅហ្នឹង ជាប់ហ្នឹង ។

ឡុង ដានី៖ យើងម៉េចដឹង?

អ៊ូ គីម៖ មើលទៅវាឃើញរបៀបដូចកំពុងធំអញ្ចឹង ។

ឡុង ដានី៖ អឺម!

អ៊ូ គីម៖ ហើយយើងចេះពិចារណាចុះមនុស្សធម្មតាម៉េចរាងខុសប្លែកដូចពីអ្នកនេះ ។ នេះវារាង .......

ឡុង ដានី៖ អ៊ូ!

អ៊ូ គីម៖ ដល់យើងចាប់ពិនិត្យបញ្ហាហ្នឹង ឃើញអាហ្នឹង ។ មួយទៀតដូចគ្នាអញ្ចឹង ។

ឡុង ដានី៖ អឺ! អ្នកហ្នឹង ភាគច្រើនដល់ពេលរួចទៅគេសម្លាប់ចោល អ្នកដែលលាក់អញ្ចឹង មិនព្រមឲ្យគេអញ្ចឹង?

អ៊ូ គីម៖ អ៊ូ! មិនរួចទេ ។ អត់រួចទេ ។

ឡុង ដានី៖ អឺម! ចុះលោកពូមានប្រសាសន៍មុនថា កាលហ្នឹងគេមានចិញ្ចឹមឆ្កែ ចញ្ចឹមអីទៀតនៅលើ...?

អ៊ូ គីម៖ បាទ! មាន ។ មានឆ្កែ មានគោ មានជ្រូក មានមាន់ មានអើ មានស្អីៗពេញទាំងអស់ ។

ឡុង ដានី៖ អ៊ូ!!

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ ថារបស់ដូចជាមាស ខ្សែក ខ្សែអី សម្បូរពេកទៅយកទៅពាក់ឲ្យឆ្កែ?

អ៊ូ គីម៖ បា! ឆ្កែកងធំគេ ។ គេពាក់ឲ្យវារត់ទៅណាទៅទៅ ។

ឡុង ដានី៖ បាត់ក៏បាត់ទៅ?

អ៊ូ គីម៖ បាទ! បាត់ទៅណាក៏បាត់ទៅ គេមិនបានគិតទេឆ្កែកងធំគេ ។ ហើយនិយាយពីចង្កៀងយើងដុតកាលហ្នឹងយើងមិនប្រើប្រេងកាត?

ឡុង ដានី៖ បាទ!

អ៊ូ គីម៖ ហើយខ្សែចង្កៀងហ្នឹងដាក់សុទ្ធតែមាសទាំងអស់ ។

ឡុង ដានី៖ សុទ្ធតែខ្សែមាស!

អ៊ូ គីមៈ បាទ! គ្មាននរណាហ៊ានទៅប៉ះពាល់ទេ។ ដាក់ណានៅហ្នឹងហើយ។ អត់មានហ៊ានទេ។ ឲ្យតែហ៊ាន គេឃើញ ដឹងតែនៅហើយ គ្មានហក់រួចទេ។

ឡុង ដានីៈ ចុះពេល ពេលដែលពួកយួនវារត់ កាលហ្នឹងមានទាំងក្មេង ទាំងចាស់ ទាំងស្រី ទាំងប្រុស?

អ៊ូ គីមៈ បាទ! មានទាំងអស់។

ឡុង ដានីៈ ភាគច្រើនចាស់ៗឬក៏ក្មេងៗ?

អ៊ូ គីមៈ ភាគច្រើនក្មេង។

ឡុង ដានីៈ ក្មេងៗ!

អ៊ូ គីមៈ មាន ៣-៤ឆ្នាំ, ៥ឆ្នាំ ឬក៏១០ឆ្នាំ។ បាទ! ភាគច្រើនគឺច្រើនតែស្ត្រី។ ហើយប្រុសៗហ្នឹងមានភាគតិច។

ឡុង ដានីៈ ប្រុសៗភាគតិចទេ?

អ៊ូ គីមៈ បាទ! ភាគតិចទេ។ ភាគច្រើនស្រីហ្នឹងហ្នុង។

ឡុង ដានីៈ ចុះហ៊ានរត់ បើទូក ទូកធំៗឬតូចៗ?

អ៊ូ គីមៈ ទូកមិនធំទេអូន។ មិនធំទេ។ ទូកតូចៗ ហើយគាត់ឆ្លងកាត់ គាត់ហ៊ានចំណាយអាយុជីវិតគាត់ឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយ ប្រើទូកខ្នាតហ្នឹង។

ឡុង ដានីៈ ហើយក្មេងៗក្នុងហ្នឹង?

អ៊ូ គីមៈ ក្មេងក្នុងហ្នឹងខ្លះ ខ្ញុំឃើញពុល អាញ៉េកអាញ៉ាកពេញទឹកពេញដីអីអញ្ចឹងទៅ ក្អួតអាឡេកអាឡាកអីអញ្ចឹងទៅ។ ហើយអាសត្វហ្នឹងក៏វាស៊ូទៅទៀត បើថាវាស្លាប់ចោលទៅ។ បើរស់វាយកទៅ។

ឡុង ដានីៈ អើម! ស្លាប់ចោលទៅ រស់យកទៅ។

អ៊ូ គីមៈ ឧទាហរណ៍ថា កូនវាហ្នឹង បើសិនជាជិះលើទូកហ្នឹង បើពុលក្អួតស្លាប់ក៏ស្លាប់ទៅ ចោលទៅ។ បើថារស់ ក៏វាយកទៅ។

ឡុង ដានីៈ អើម! ហើយ រត់ពីណាទៅណា បើតាមទិសដៅរបស់គេ?

អ៊ូ គីមៈ អើ! ពីប្រទេសយួនហ្នឹង ច្រើនទៅសិង្ហបុរី ទៅខាងហ្វីលីពីន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

ឡុង ដានីៈ ប៉ុន្តែសមុទ្រហ្នឹងចេញអញ្ចឹង ចេញទៅខាងសិង្ហបុរី ទៅហ្វីលីពីនហើយណ៎?

អ៊ូ គីមៈ បាទ! ហ្នឹងវាថា វាតាមការសួរទៅ វាទៅហ្នឹងទៅវិញ។ ប៉ុន្តែផ្លូវហ្នឹងវាទៅណា កាច់បត់កន្លែងណាអី យើងអត់ដឹងទេ។

ឡុង ដានីៈ អើម! ចុះ អ្នកដែលដូចថាចាប់បានស្រីៗ មានដែល គេចាប់ពួកហ្នឹងមក យកមកធ្វើប្រពន្ធធ្វើអីដែរទេ?

អ៊ូ គីមៈ អត់! អត់ទេ!

ឡុង ដានីៈ អត់ទេ!

អ៊ូ គីមៈ បាទ! សូម្បីតែទៅឡេសឡោះក៏អត់បានដែរ។

ឡុង ដានីៈ អើម!

អ៊ូ គីមៈ គឺវិន័យម៉ឹងម៉ាត់ហ្នឹង។

ឡុង ដានីៈ អើម!

អ៊ូ គីមៈ សូម្បីតែនិយាយហ្នឹង គេឲ្យសួរ ឧទារហណ៍ថាសួរពីស្អី ត្រូវតែសួរពីហ្នឹង។ អត់មានទៅខុសចាកប្រធានទៅនិយាយជាមួយទៀត អត់បានទេ។ វិន័យគេតឹងណាស់។

ឡុង ដានីៈ ចុះក្មេងៗតូចៗ យើងយកមកចញ្ចឹមបានអត់ទេ?

អ៊ូ គីមៈ អត់! អត់បានទេ! សូម្បីតែកាន់ គេមិនឲ្យយើងយកទៅកាន់ផង។

ឡុង ដានីៈ មិនឲ្យកាន់?

អ៊ូ គីមៈ បាទ! យើងយាមនៅតែយាម។ ឧទាហរណ៍ គេនៅហ្នឹង យើងនៅតែហ្នឹង។ អត់មានទៅយ៉ោយ៉ាវញ៉េរញ៉ៃបានទេ។

ឡុង ដានីៈ បើគេបញ្ជាឲ្យយើងសម្លាប់ សម្លាប់ទៅ?

អ៊ូ គីមៈ បាទ! បើអ្នកទៅយាមហ្នឹង បើសិនជាគេត្រូវឲ្យចាប់អ្នកហ្នឹងទៅធ្វើអី សម្លាប់អី ក៏គេយកទៅសម្លាប់ទៅ។

ឡុង ដានីៈ ក្មេងក៏គេសម្លាប់ដែរ គេមិនទុកទេ?

អ៊ូ គីមៈ គេមិនដែលថាគិតថាក្មេងថាចាស់ទេអូន។

ឡុង ដានីៈ ហើយ! ហើយអ្នករត់ហូរហែររហូតតាំងពី៧៥រហូតដល់៧៩?

អ៊ូ គីមៈ ហូរហែររហូត។ ខ្ញុំឃើញតែរត់រហូត។

ឡុង ដានីៈ ច្រើនឆ្នាំណា ច្រើនបំផុតទៅ បើតាមចាំ?

អ៊ូ គីមៈ អូន ចាប់ពី៧៦មកហ្នឹង ឃើញហូរហែររហូត។

ឡុង ដានីៈ ដូចប៉ុន្មានថ្ងៃម្តង បើយើងស្មាន?

អ៊ូ គីមៈ ប្រហែល ជួនកាលកន្លះខែម្តង។ ហើយម្តងៗមិនតិចទេ៥០-៦០នាក់ ១០០នាក់។

ឡុង ដានីៈ អើម!

អ៊ូ គីមៈ បាទ! ហើយតិចៗ មកទៀត។ តិចៗមកទៀត។ ខ្ញុំឃើញញយណាស់។

ឡុង ដានី៖ ប៉ុន្តែរត់ហ្នឹងភាគច្រើនចាប់បាន ឬក៏មានរួចទៅច្រើនដែរ?

អ៊ូ គីម៖ មិនងាយរួចទេអូន។

ឡុង ដានី៖ មិនងាយរួចទេ?

អ៊ូ គីម៖ ព្រោះគេត្រូវការកប៉ាល់ដែលមានល្បឿនលឿននៅកំពង់សោម។ គេសម្រាប់ចាប់ពួកអស់ហ្នឹង។

ឡុង ដានី៖ បើតាមជំនាន់ស្នានមើល បើយើងចាប់តាំងពី៧០.. ពីដើម ពី៧៥-៧៦ រហូតដល់៧៩ យើងរត់ហ្នឹង ប្រហែលជាប៉ុន្មាន បើតាមស្មាន?

អ៊ូ គីម៖ អើម! បញ្ហាហ្នឹងវាពិបាកត្រង់ថា ការយល្លេហ្នឹងខ្លាចវាមិនពិតដូច។

ឡុង ដានី៖ បើយើងស្មាន គ្រាន់តែស្មាន។ ហ្នឹងយើងមិនអាចថា ស្មានវាអាថាលើសខ្លះ អាចថាខ្វះខ្លះហើយ។

អ៊ូ គីម៖ តែនេះជាការស្មាន បើខ្ញុំធ្លាប់ដឹងមិនក្រោមពី១០០០។

ឡុង ដានី៖ មិនក្រោមពី១០០០ទេ?

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ ហើយក្នុង១០០០ អាចថាមានគេបញ្ជូនទៅណាទៅណីខ្លះ ឬក៏គេចាត់ការនៅកោះលើកោះហ្នឹងទាំងអស់?

អ៊ូ គីម៖ បញ្ហាលើកោះហ្នឹងមួយចំនួនដែលគេត្រូវតែបញ្ចប់ដំណើររបស់គាត់។ ហើយមួយចំនួនទៀត មិនដឹងគេបញ្ជូនទៅណា ព្រោះគេថា គេបញ្ជូនៗហើយបញ្ជូនហ្នឹង។ បើសិនគេបញ្ជូន គេបើកឲ្យទូកហ្នឹង ជិះលើទូកហ្នឹងបើកទៅណាទៅទៅ។ គេអត់រករឿងទេ ហ្នឹងគេបញ្ជូនទៅវិញ។ តែបើសិនជាគេមិនបញ្ជូនទេ គេអត់ឲ្យទូកហ្នឹងទៅវិញទេ។ គេដោយចាត់ការតាមវិធីរបស់គេ។

ឡុង ដានី៖ ហើយទូកគេយកធ្វើអីទៅទូក?

អ៊ូ គីម៖ ទូកមានធ្វើអីអូន គ្រាន់អូសត្រីអីដាក់មង។ យកអាទូកហ្នឹងដាក់មង ក្បែរៗកោះ។ តិចៗ ជិតៗហ្នឹង។

ឡុង ដានី៖ ហើយបើតាមការជំនាន់ស្មានមួយចំនួនដែលគេ ចាត់ការនៅលើកោះហ្នឹងប្រហែលប៉ុន្មានដែរ? បើគិតតាមពូស្មាន?

អ៊ូ គីម៖ ច្រើនដែរអូន។

ឡុង ដានី៖ អាចដល់ខ្ទង់រយឬក៏?

អ៊ូ គីម៖ រយ! រយជាង។

ឡុង ដានី: ប៉ុន្មានទៅ បើតាមស្មាន?
អ៊ូ គីមៈ ប្រហែលជា បើតាមខ្ញុំដឹង ប្រហែលជាក្រោម៥០០ ។
ឡុង ដានី: ក្រោម៥០០?
អ៊ូ គីមៈ បាទ!
ឡុង ដានី: ប្រហែលក្រោមប៉ុន្មាន ៥០០? ក្រោមអាច?
អ៊ូ គីមៈ ប្រហែលជាអាច៣០០ទៅ៤០០ ។
ឡុង ដានី: ៣០០ទៅ៤០០?
អ៊ូ គីមៈ បាទ!
ឡុង ដានី: ហើយអ្នកដែលគេសម្លាប់ហ្នឹង គេសម្លាប់តែមួយកន្លែងហ្នឹង ឬក៏សម្លាប់ពាសវាល ពាសកាល?
អ៊ូ គីមៈ អត់មានមួយកន្លែងទេ ។ គេសម្លាប់ហ្នឹងមិនមែនមួយកន្លែងទេ ។ គេសម្លាប់ហ្នឹង គេ ចែកជានេះ គេចែកជាមនុស្ស ។ ចែកនេះប៉ុន្មាន នោះប៉ុន្មានអញ្ចឹង ។ គេអត់ដាក់គរ គ្នាទេ ។ ហើយថៃហ្នឹងក៏ដូចគ្នាដែរ ។
ឡុង ដានី: ពួកនេសាទថៃក៏ច្រើនដែរ?
អ៊ូ គីមៈ ក៏ច្រើនដែរ ។ ហ្នឹងក៏គេចែកគ្នាដែរ ។ គេមិនដាក់តម្កល់ជាមួយកន្លុកៗទេ ។
ឡុង ដានី: នេសាទហ្នឹងយ៉ាងម៉េចពូអាចរៀបរាប់ពួកអ្នកនេសាទថៃ?
អ៊ូ គីមៈ នេសាទថៃ គឺថាយើងមកនេសាទក្នុងទឹកដីរបស់គេ ។ បានន័យថារំលោភយកទ្រព្យ សម្បត្តិមច្ឆជាតិរបស់គេ ។ គេគិតថាអញ្ចេះ បើថា បើអ្នកឯងមិនចូលមក ក៏គេមិនថា អីដែរ ប៉ុន្តែអ្នកចូលមកអ្នកឯងល្មើសមិនគោរពច្បាប់របស់គេ ។
ឡុង ដានី: ល្មើស!!!
អ៊ូ គីមៈ មិនគោរពច្បាប់របស់គេ ។
ឡុង ដានី: បាទ! មិនគោរពច្បាប់ ។ ហើយក្នុងអ្នកនេសាទមួយទូកៗ ប៉ុន្មាននាក់ទៅ?
អ៊ូ គីមៈ ច្រើនដែរអូន ៣៦-៣៧នាក់ ។
ឡុង ដានី: មួយទូកវាធំដែរអញ្ចឹង?
អ៊ូ គីមៈ បាទ! ទូកសុទ្ធតែអា៨០០ ទៅ ១០០០ ។
ឡុង ដានី: ១០០០សេសអីហ្នឹង?
អ៊ូ គីមៈ បាទ! មិនធម្មតា ។
ឡុង ដានី: ប៉ុន្មានតោនទូកប៉ុណ្ណឹង?

អ៊ូ គីមៈ ច្រើនណាស់អូន។ ក្នុកវា២ៗដូរ។
ឡុង ដានីៈ ហើយបើចាប់បានមួយហ្នឹងត្រីឬក៏?
អ៊ូ គីមៈ ផ្ញើកន្លះខែ!
ឡុង ដានីៈ ផ្ញើកន្លះខែ?
អ៊ូ គីមៈ បាទ! ផ្ញើកន្លះខែ។
ឡុង ដានីៈ រួចហូបប៉ុន្មាន?
អ៊ូ គីមៈ ហូបមួយឆ្នាំមិនអស់ផង។
ឡុង ដានីៈ ឲ្យតែចាប់បានមួយទូក?
អ៊ូ គីមៈ បាទ!
ឡុង ដានីៈ ហើយអ្នកនេសាទហ្នឹងមានកាំភ្លើង?
អ៊ូ គីមៈ អត់មាន! អាចមានកាលីខ្លះ កាលីខ្លះ កាំភ្លើងគ្រាប់សំណ ក៏ប៉ុន្តែកាលីដូណា ក៏មិននៅហ្នឹងគេដែរ ព្រោះគេមានកាំភ្លើង។
ឡុង ដានីៈ ហើយទូកនេសាទថៃហ្នឹងច្រើនទេ?
អ៊ូ គីមៈ ច្រើន! កាលមុនចាប់បានច្រើនណាស់។
ឡុង ដានីៈ ប្រហែលជាប៉ុន្មានទៅ បើប្រៀបធៀបជាមួយអ្នករត់មកពីស្រុកយួនអី ទូកនេសាទថៃមួយណាច្រើនជាង?
អ៊ូ គីមៈ អ៊ូ! ថៃច្រើនជាង។
ឡុង ដានីៈ ថៃច្រើនជាង?
អ៊ូ គីមៈ បាទ! ថៃច្រើនជាង។
ឡុង ដានីៈ ហើយពួកថៃក៏ច្រើនតែស្លាប់នៅលើកោះហ្នឹងដែរ?
អ៊ូ គីមៈ ខ្ញុំមិនដែលឃើញនរណានៅរស់ទេ។
ឡុង ដានីៈ មិនឃើញមួយ?
អ៊ូ គីមៈ បាទ!
ឡុង ដានីៈ មានបញ្ជូនទៅកំពង់សោមទេ?
អ៊ូ គីមៈ អាចបញ្ជូនមកខ្លះ។
ឡុង ដានីៈ អាចមកខ្លះ?
អ៊ូ គីមៈ បាទ! អាចប្រលែង ឧទាហរណ៍ថាចាប់បានអញ្ចឹងឲ្យវាជិះទូកទៅវិញ។ ហ្នឹងមានទៀត។

ឡុង ដានី៖ ចុះករណីដែលប្រលែងវិញ មូលហេតុអ្វីបានប្រលែងវិញ?

អ៊ូ គីម៖ អើម!អូនអើយ ចំណុចហ្នឹងខ្ញុំពិបាកនឹងពន្យល់ណាស់ ព្រោះគេមេ ហើយយើងមិនដឹងថាបទបញ្ជា ពីថ្នាក់លើបញ្ជាមកគេយ៉ាងម៉េច ។ យើងអត់ដឹង ។ អញ្ចឹង! យើងដឹងថាឃើញជាក់ស្ដែង ហើយរឿងរ៉ាវយើងបានដឹងតែប៉ុណ្ណឹងទេ ។

ឡុង ដានី៖ អើម! អញ្ចឹង! ពួកយួនដែលរត់អាចប្រហែលជាចន្លោះពី៤០០ទៅ៣០០សម្លាប់នៅកោះហ្នឹង?

អ៊ូ គីម៖ បា៎ទ!

ឡុង ដានី៖ ចុះពួកនេសាទ ពួកថៃប្រហែលជាប៉ុន្មាន បើយើងប៉ាន់ស្មាន? អាចខ្ទង់?

អ៊ូ គីម៖ អត់ទេអូនអើយ!

ឡុង ដានី៖ អាចច្រើនជាង៣០០-៤០០ហ្នឹងឬក៏តិចជាង?

អ៊ូ គីម៖ វាអាចច្រើនជាង ។

ឡុង ដានី៖ ភាគច្រើនប្រុសៗ ឬក៏មានស្រីៗដែរ?

អ៊ូ គីម៖ អត់មានស្រីទេ មានតែប្រុស ។

ឡុង ដានី៖ អ្នកនេសាទច្រើនតែប្រុសទេ?

អ៊ូ គីម៖ បា៎ទ!

ឡុង ដានី៖ បើពួករត់ ពួកយួន ភាគច្រើនស្រី ។

អ៊ូ គីម៖ ស្រី!

ឡុង ដានី៖ ស្រីហើយក្មេង?

អ៊ូ គីម៖ បា៎ទ!

ឡុង ដានី៖ ចុះពេលគេសម្លាប់ហើយ ខោអាវអី គេមានប្រមូលទៅយកខោអាវ?

អ៊ូ គីម៖ មិនដែលគិតរឿងខោអាវ រឿងអីទេ ។

ឡុង ដានី៖ អូ៎!

អ៊ូ គីម៖ គេមិនយកទេ ។

ឡុង ដានី៖ គេមិនយកទេ?

អ៊ូ គីម៖ បា៎ទ!

ឡុង ដានី៖ តែពួកនេសាទ ពួកថៃអីហ្នឹង ដូចរបស់មានតម្លៃគឺមានដែរអត់?

អ៊ូ គីម៖ អត់មានអីទេ ។

ឡុង ដានី៖ អត់មានទេ?

អ៊ូ គីមៈ ប៉ាទ! ខុសពីត្រីហ្នឹងគឺអត់មាន ។ អត់មានយកអារបស់មានតម្លៃអីទៅ ។

ឡុង ដានីៈ ពួកឃួន ពួកស្រីៗបានមាន?

អ៊ូ គីមៈ មាន ។

ឡុង ដានីៈ របស់មានតម្លៃភាគច្រើនគឺមាសហ្នឹងហ្ន៎ង?

អ៊ូ គីមៈ មាសហ្នឹងហ្ន៎ង ។

ឡុង ដានីៈ អើម! លុយកាក់អី អត់មានទេ ។

អ៊ូ គីមៈ មានដែរ មានតិចតួច ។

ឡុង ដានីៈ មានតិចតួច?

អ៊ូ គីមៈ ប៉ាទ! នឹកឃើញថា វាមិនដឹងជាចាយអីក្នុងទឹកហ្នឹង ។ វាអត់យកទៅច្រើនទេអូន ។ ជួនកាល វាច្រលំជាប់កប៉ាល់មិនទាន់បានទៅប្រាំង ។ តែប៉ុណ្ណឹងទេ ។

ឡុង ដានីៈ ចុះ តាមុត គាត់អាចដឹងទេនូវរឿងទាក់ទងរឿងចាប់?

អ៊ូ គីមៈ រឿងចាប់ រឿងគាត់ គាត់ដឹងហើយ ។ និយាយរឿងអីដែលមិនដឹង ។ គេអូឆ្លងឆ្លើយគ្នា វាយទូរលេខឆ្លងឆ្លើយគ្នា ។ ក៏ប៉ុន្តែមិនដឹងជាផែនការគាត់យ៉ាងម៉េចអី ថ្នាក់លើបញ្ជាមកគាត់យ៉ាងម៉េចអី យ៉ាងម៉េចខ្ញុំអត់ដឹង ។ ខ្ញុំវាកូនទាហានគេ ប៉ុន្តែគ្រាន់ថា ។

ឡុង ដានីៈ ចុះអ្នកដែលគេសម្លាប់លើកោះហ្នឹង គាត់តាមមើលយ៉ាងម៉េច គាត់ក៏ដឹងដែរហើយក៏មិនដឹងទេ?

អ៊ូ គីមៈ គ្មានរឿងអីដែលមិនដឹងទេ ។ ធ្វើមេដឹកនាំគេរឿងអីដែលមិនដឹងនោះ ។ ឧទាហរណ៍ថាឥឡូវ ឧទាហរណ៍ថា ចាប់បានថ្ងៃនេះ៣០នាក់ ។ យើងត្រូវតែសួរ គាត់ត្រូវតែសួរ ៣០នាក់ហ្នឹងលែងគេទៅវិញនូវ? ហ្នឹងធាតុពិតគឺត្រូវតែសួរគេអញ្ចឹង ។ ហើយបើសិនជាគាត់ថា ត្រូវធ្វើម្ហូបធ្វើម្ហារអី ហ្នឹងគាត់និយាយតាមទូរលេខហ្នឹងមក ។ កាលហ្នឹងអត់មានគេអូ អត់មានទូរសព្ទទេ ។ និយាយប្រើទូរលេខទាំងអស់ ។

ឡុង ដានីៈ អ៊ូ!

អ៊ូ គីមៈ អាទីត ទីត ទីតហ្នឹង ។

ឡុង ដានីៈ អើម! កាលជំនាន់ហ្នឹងពាក្យនេះគេ គេហៅធ្វើម្ហូបធ្វើអាហារហ្នឹង?

អ៊ូ គីមៈ ប៉ាទ!

ឡុង ដានីៈ ហ្នឹងគេបានន័យថាសម្លាប់ហើយ?

អ៊ូ គីមៈ ប៉ាទ!

ឡុង ដានីៈ គេថាធ្វើម្ហូបទៅ?

អ៊ូ គីមៈ ម្ហូបទៅ!

ឡុង ដានីៈ ធ្វើម្ហូប!

អ៊ូ គីមៈ ខ្ញុំនិយាយទៅ ៥ឆ្នាំ ៦ឆ្នាំនេះ កាលជំនាន់ហ្នឹង ខ្ញុំអត់ដែលបានឃើញដីគោកម៉េចទេ ។

ឡុង ដានីៈ ពេលដែលពូមានប្រសាសន៍មុនហ្នឹងថា តាមុត គាត់ខស្ប្រាហ៍ទៅដែរ? ខស្ប្រាហ៍យក?

អ៊ូ គីមៈ ទៅ!

ឡុង ដានីៈ ទៅកោះពូលូវៃហ្នឹង?

អ៊ូ គីមៈ បាទ! ទៅញឹកណាស់ ។

ឡុង ដានីៈ ហើយគាត់មានដែលទៅមើលឃើញពួកសាកសពអី រណ្ដៅ?

អ៊ូ គីមៈ អ៊ូ! អត់ទេអូន ។ គេមិនឲ្យយើងដឹងទេ ។

ឡុង ដានីៈ មិនដឹងគាត់ទៅមើលឬអត់ទេ?

អ៊ូ គីមៈ អត់ដឹងទេ!

ឡុង ដានីៈ ហើយទៅគាត់មានដែលណែនាំអី ពួករត់ ពួកខ្មាំង ពួកអី មកអី?

អ៊ូ គីមៈ គាត់និយាយតែពីរឿងការពារទឹកដី ការពារដែនសមុទ្រកោះអីអញ្ចឹងទៅ កុំឲ្យខ្មាំងសត្រូវឈ្លានពានអី ។ តែរឿងសម្លាប់ រឿងអី ថ្នាក់ក្រោមហ្នឹងប្រហែលជាក្រោមហ្នឹងបិទលើហ្នឹងទៀតពត៌មានហ្នឹង ឬក៏លើបញ្ឆោទៅហ្នឹងបិទគ្នាយ៉ាងម៉េច គេសង់តង់គ្នាយ៉ាងម៉េច ខ្ញុំមិនដឹងទេ ។ ប៉ុន្តែខ្ញុំឃើញ ។

ឡុង ដានីៈ គាត់ទៅគាត់ច្រើនស្លៀកពាក់ខោអាវអីទៅ តាមុត?

អ៊ូ គីមៈ ខោអាវខ្មៅ ហើយបង់កក្រមា ។

ឡុង ដានីៈ ខោអាវខ្មៅបង់កក្រមា ។ ពាក់មួក ពាក់អីទេ?

អ៊ូ គីមៈ ពាក់មួក ។

ឡុង ដានីៈ មួកកាលជំនាន់ហ្នឹងពណ៌ម៉េច?

អ៊ូ គីមៈ ខៀវ!

ឡុង ដានីៈ ពណ៌ខៀវ?

អ៊ូ គីមៈ បាទ! ដើងទឹក១៦៨ខៀវ ។

ឡុង ដានីៈ ខោវអាវខ្មៅ?

អ៊ូ គីមៈ ខោអាវ បើពួកកប៉ាល់ហ្នឹងខៀវ ប៉ុន្តែបើពួកកងទ័ពខ្មៅ ។

ឡុង ដានីៈ ដូចពូដើងគោកកងទ័ពខ្មៅ?

អ៊ូ គីមៈ ខ្មៅ!

ឡុង ដានីៈ ហើយបើពូបើកកប៉ាល់ពណ៌ខៀវ?

អ៊ូ គីមៈ ខៀវ!

ឡុង ដានីៈ ខៀវហ្នឹងរបៀប?

អ៊ូ គីមៈ ខៀវហ្នឹង! នោះខៀវរបៀបកៅអីនោះ។ ថ្នាំកៅអី។

ឡុង ដានីៈ ពណ៌ខៀវ ពណ៌ដូចពណ៌ផ្ទៃមេឃអីវិញ។

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ពណ៌ខៀវកៅអី។ ហ្នឹងពណ៌ blue។ ហើយដល់ពេល តាមុត គាត់ពាក់អាវខ្មៅដែរ?

អ៊ូ គីមៈ ខ្មៅ!

ឡុង ដានីៈ ហើយពាក់មួក មួកពណ៌ខៀវអញ្ចឹងវិញ?

អ៊ូ គីមៈ ខៀវ!

ឡុង ដានីៈ ខៀវម៉េចមួកគាត់?

អ៊ូ គីមៈ មួកដើរទឹក មួកដូចនេះអញ្ចឹង ដូចខៀវដូចជាអញ្ចឹង។ ប៉ុន្តែបើមួកកម្មាភិបាល មួកកងទ័ពអត់ខៀវអញ្ចឹងទេ។

ឡុង ដានីៈ មួកម៉េចវិញ?

អ៊ូ គីមៈ មួកហ្នឹងម៉េចទេ ភ្លេចបាត់ហើយមួក។

ឡុង ដានីៈ មួកដូចស៊ីមីលី ឬក៏ខុសគ្នា?

អ៊ូ គីមៈ របៀបស៊ីមីលីហ្នឹងហើយ។ របៀបហ្នឹង

ឡុង ដានីៈ ពាក់ក្រោយ៧៩ហ្នឹង?

អ៊ូ គីមៈ បាទ! របៀបមួក។

ឡុង ដានីៈ កន្ទីបៗអញ្ចឹង។

អ៊ូ គីមៈ កន្ទីបដូចគ្នាអញ្ចឹង។

ឡុង ដានីៈ តាមុត គាត់ពាក់មួកហ្នឹងដែរ?

អ៊ូ គីមៈ គាត់ពាក់មួកហ្នឹងដូចតែគ្នាហ្នឹង។

ឡុង ដានីៈ ហើយស្បែកជើង?

អ៊ូ គីមៈ ស្បែកជើងដឹកយកពីចិនមក។

ឡុង ដានីៈ ស្បែកជើងពីចិន។ ស្បែកជើងពុម្ពហ្នឹង?

អ៊ូ គីមៈ បាទ! ស្បែកជើងពុម្ពហ្នឹង គេបោះមកពីចិន។

ឡុង ដានីៈ ហើយពូក៏ពាក់អញ្ចឹងដែរ?

អ៊ូ គីមៈ ខ្ញុំក៏ពាក់អាហ្នឹងដែរ។ អាពុម្ពហ្នឹង។

ឡុង ដានីៈ ស្បែកជើងពុម្ពហ្នឹង។

អ៊ូ គីមៈ ហ្នឹង!

ឡុង ដានីៈ ហើយមានអង្គរក្សមានអីទៅច្រើនដែរពេលគាត់ទៅកោះម្តងៗ?

អ៊ូ គីមៈ មិនដែលបានទៅជិតគាត់តាមដានការងារហ្នឹង។ ឃើញទៅ ឃើញអង្គរក្សឆ្ងូងឆ្ងារដែរ។ យើងតូចតាច មិនប៉ាច់ទៅនេះទេ។ វីវររញ៉េរញ៉ៃអី គេចោទប្រកាន់យើងថា យើងខាងបក្ស ខាងអង្គការអីហ្នឹង ចោលខ្មោចទៀតឥឡូវហ្នឹង។

ឡុង ដានីៈ ពូខ្ញុំចង់បញ្ជាក់ពូបន្តិចទាក់ទងពីរចនាសម្ព័ន្ធកងពល។ កងពល១៦៤ មាស មុត គាត់ធ្វើប្រធាន។ អនុប្រធានពីណាគេ?

អ៊ូ គីមៈ មានឈ្មោះ អ៊ឹម មួយទៀត។ អ៊ឹម មានតើ?

ឡុង ដានីៈ ឈ្មោះ អ៊ឹម?

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ឈ្មោះអីទៀត? លោកពូមានប្រសាសន៍ថាឈ្មោះ សេង គាត់ធ្វើអីដែរ?

អ៊ូ គីមៈ សេង។ តាសេង កងពលដូចតែគ្នាហ្នឹង។

ឡុង ដានីៈ សេង ហ្នឹងក៏កងពលដែរ ប៉ុន្តែតូចជាង តាមុត ទេ?

អ៊ូ គីមៈ បាទ! តាមុត ធំជាង។ ហើយមានឈ្មោះ អ៊ឹម មួយទៀត?

ឡុង ដានីៈ ឈ្មោះ អ៊ឹម មួយទៀត។

អ៊ូ គីមៈ បាទ! មានមួយទៀត។

ឡុង ដានីៈ អើម!

អ៊ូ គីមៈ ហើយធ្លាក់មកបាន តាយាង។ វរសេនាធំ ប្រធាន។

ឡុង ដានីៈ យាង វរសេនាធំលេខប៉ុន្មាន?

អ៊ូ គីមៈ បាទ! ៦៣។

ឡុង ដានីៈ ៦៣?

អ៊ូ គីមៈ ឈ្មោះ តាយាង ហ្នឹង៦៣។ ហើយឈ្មោះ តាសារឿន ហ្នឹង៦៣ដែរ។

ឡុង ដានីៈ យាង, សារឿន ហើយ យាង ហើយ សារឿនហ្នឹងណាធំជាង?

អ៊ូ គីមៈ តាយាង ធំជាង។

ឡុង ដានីៈ សារឿន អនុអញ្ចឹង?

អ៊ូ គីមៈ បាទ!

ឡុង ដានី: យាន ធ្វើប្រធាន។ ហ្នឹងវរសេនាធំ៦២ របស់អស់ហើយលោកពូ?

អ៊ូ គីម: វរសេនាធំ៦២ហ្នឹងគឺ ប្រធានវរសេនាធំហ្នឹងគឺ នៅក្នុងកងពល ប្រធានវរសេនាតូច ហ្នឹង គឺក្រោមចំណុះវរៈសេនាធំហ្នឹង។

ឡុង ដានី: វីរសេនាធំ៦២ យាន ហ្នឹង គាត់ឈរនៅណា? វរសេនាធំ។

អ៊ូ គីម: គាត់ឈរនៅកោះតាង។

ឡុង ដានី: នៅកោះតាង។ អញ្ចឹង! វរសេនាធំ៦២ នៅកោះតាង។ យាន ហើយ សារឿនហ្នឹង គាត់ឈរនៅកោះតាងហ្នឹងអត់?

អ៊ូ គីម: បាទ! ឈរនៅកោះតាង។

ឡុង ដានី: យានហ្នឹង គាត់តែងនៅណាដែរ?

អ៊ូ គីម: យាន ហ្នឹងប្រហែលជាម្ដុំហ្នឹង បើមិនកោះកុង ស្រែអំបិល។ បើមិនសំឡូត ស្រែ អំបិល។

ឡុង ដានី: បើមិនសំឡូតទេ ស្រែអំបិល?

អ៊ូ គីម: ស្រែអំបិល!

ឡុង ដានី: គាត់នៅរស់ទេមើលទៅ?

អ៊ូ គីម: ដូច តាបូ សុទ្ធតែនៅរស់ទាំងអស់។ នៅស្រែអំបិល។

ឡុង ដានី: តាបូ គាត់អ្នកណានៅក្នុងណាដែរ? តាបូ គាត់ធ្វើអី?

អ៊ូ គីម: តា បូ គាត់ប្រធានខាង១៦៤ហ្នឹង ខាងជើងទឹក។

ឡុង ដានី: ខាងជើងទឹក?

អ៊ូ គីម: បាទ!

ឡុង ដានី: បាទ! អញ្ចឹង! វរសេនាធំមាន យាន មាន សារឿន មានពីណាទៀតដែរអត់ទេ?

អ៊ូ គីម: ខ្ញុំអត់ដឹងអស់ទេ ប៉ុន្តែវាអាចមានបន្តៗទៀត។

ឡុង ដានី: ប៉ុន្តែ សារឿន គាត់នៅរស់ដែរអត់ទេ?

អ៊ូ គីម: សារឿន ស្លាប់ហើយ។ ទើបស្លាប់នេះ លើកមុននេះ។

ឡុង ដានី: នៅណា?

អ៊ូ គីម: បាទ! នៅភ្នំព្រឹកនេះ។

ឡុង ដានី: ទើបស្លាប់ពីកាល?

អ៊ូ គីម: ស្លាប់ហើយ៤-៥ឆ្នាំមុននេះ។

ឡុង ដានី: ស្លាប់៤-៥ឆ្នាំមុន។

អ៊ូ គីមៈ បាទ! យកទៅដល់ចិនទៀត ប៉ុន្តែចិនព្យាបាលអត់រួច ។

ឡុង ដានីៈ គាត់ឈឺអី?

អ៊ូ គីមៈ ឈឺស្អីទេ? មហារីកម៉េចទេ?

ឡុង ដានីៈ គាត់ធ្វើធំដែរ?

អ៊ូ គីមៈ ហ្នឹងហើយធំ ។

ឡុង ដានីៈ បាទ! អញ្ចឹង! ក្នុងវរសេនាធំ៦២ហ្នឹង មានវរតូចអីខ្លះ? លេខប៉ុន្មានខ្លះ?

អ៊ូ គីមៈ ៦២១, ៦២២ ។

ឡុង ដានីៈ ៦២១, ៦២២ ។

អ៊ូ គីមៈ អើម!

ឡុង ដានីៈ តែ២ហ្នឹងទេ?

អ៊ូ គីមៈ មានទៀតអូន ។ មានទៀត ។

ឡុង ដានីៈ វរសេនាតូចប៉ុន្មានទៀត?

អ៊ូ គីមៈ វាមិនដឹងថា វរសេនាតូចណាទៀត ។

ឡុង ដានីៈ ចុះវរសេតូច៦២១ឈរនៅណា?

អ៊ូ គីមៈ ៦២១ឈរកោះថ្មី ។ ពូលូវៃថ្មី ។

ឡុង ដានីៈ កោះពូលូវៃថ្មី?

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ថ្មី! ពីណាគេ អ្នកប្រធានវរសេនាតូច?

អ៊ូ គីមៈ តាណន ។

ឡុង ដានីៈ ឈ្មោះ ណន?

អ៊ូ គីមៈ ណន ។

ឡុង ដានីៈ ណន?

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ណន គាត់នៅរស់ទេឬក៏?

អ៊ូ គីមៈ មិនទាន់ស្លាប់ ណនហ្នឹង ។

ឡុង ដានីៈ នៅណា?

អ៊ូ គីមៈ ប៉ុន្តែមិនដឹងនៅណា ។ ប្រហែលជានៅដងរែក ។ អ៊ូ! នៅដងរែក ។

ឡុង ដានីៈ ដងរែកនៅណាទៅ?

អ៊ូ គីមៈ នៅស៊ីសាកេត ដងវែកហ្នឹង ។

ឡុង ដានីៈ ខាងខេត្តអីគេឥឡូវ?

អ៊ូ គីមៈ ខាងអន្លង់វែង ។

ឡុង ដានីៈ ហ្នឹងអន្លង់វែង?

អ៊ូ គីមៈ បា៉ទ!

ឡុង ដានីៈ អត់ដែលជួបគាត់ទេ?

អ៊ូ គីមៈ អត់ទេ! អត់ដែលទេ ។

ឡុង ដានីៈ ណាន! អនុគាត់ពីណាគេ ណាន?

អ៊ូ គីមៈ អនុ តាម៉េត ។

ឡុង ដានីៈ ឈ្មោះ ម៉េត?

អ៊ូ គីមៈ បា៉ទ!

ឡុង ដានីៈ តាខ្វាក់ភ្នែក មួយចំហៀងហ្នឹង?

អ៊ូ គីមៈ បា៉ទ! ហ្នឹងហើយ ។ តាម៉េត ហ្នឹងបែបនៅទេ ។

ឡុង ដានីៈ នៅណាដែរ?

អ៊ូ គីមៈ ប្រហែលជានៅស្រែអំបិល ។ នៅជិត តាបូ ។

ឡុង ដានីៈ ហើយវរសេនាតូចមានប៉ុន្មានអនុសេនាធំ កងធំ?

អ៊ូ គីមៈ វាមាន៤កងធំ ។

ឡុង ដានីៈ ៤កងធំទៀត ។

អ៊ូ គីមៈ កងកាំភ្លើធំ១ ។ ថ្មើរជើង៣ ។

ឡុង ដានីៈ ថ្មើរជើង៣ ។ មានបីទៀត ហើយលោកពូនៅក្នុងកងធំមួយណា?

អ៊ូ គីមៈ ខ្ញុំនៅ១៥ ។

ឡុង ដានីៈ កងធំ១៥ ដប់ប៉ុន្មានខ្វះ?

អ៊ូ គីមៈ ១៦, ១៧, ១៨ ។

ឡុង ដានីៈ កងកាំភ្លើងធំហ្នឹង ដប់ប៉ុន្មាន?

អ៊ូ គីមៈ ១៨ ។

ឡុង ដានីៈ ១៨! ហើយពូនៅកង១៥ ។

អ៊ូ គីមៈ ១៥!

ឡុង ដានីៈ ហើយចុះ វរសេនាធំ៦២២នៅកោះណាហ្នឹង?

អ៊ូ គីមៈ ខ្ញុំអត់ដឹងអូន។ កុំឲ្យនិយាយទៅ វានេះ។

ឡុង ដានីៈ វាខុស!

អ៊ូ គីមៈ បាទ! វាខុស។

ឡុង ដានីៈ លោកពូដឹងថាវរសេនាធំ២១នៅកោះថ្មី។

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ចុះកោះចាស់ ពូលូវៃចាស់?

អ៊ូ គីមៈ កោះចាស់ប្រហែល២១, ២២ ហ្នឹង។ ២១នេះកោះថ្មី ២២នេះកោះចាស់។

ឡុង ដានីៈ ចាស់! ប្រធានគេស្គាល់ឈ្មោះគាត់អត់? ប្រធាន៦២២?

អ៊ូ គីមៈ ភ្លេចអស់ហើយ ។

ឡុង ដានីៈ ភ្លេចហើយ។

អ៊ូ គីមៈ ភ្លេចហើយ ច្រើនពេកហើយ មិនបានចាប់អារម្មណ៍។

ឡុង ដានីៈ ហើយចុះវរសេនាធំ អើ! មិញវរសេនាធំ៦២នៅកោះតាងឈ្មោះយាង ឈ្មោះសារឿន ចុះវរសេនាធំផ្សេងទៀត មានឈ្មោះអីខ្លះទៀតទៅ?

អ៊ូ គីមៈ ខ្ញុំអត់ដឹង។

ឡុង ដានីៈ មានតែមួយវរសេនាធំ៦២ទេ?

អ៊ូ គីមៈ មានទៀត ប៉ុន្តែខ្ញុំអត់បានស្គាល់ទៅដល់វរសេនាធំហ្នឹង។ និយាយអត់បានទេ និយាយហ្នឹងវាចាកប្រធាន។ មិនហ៊ាននិយាយទេ។

ឡុង ដានីៈ អត់ហ៊ាននិយាយទេ។ ស្គាល់

អ៊ូ គីមៈ សួរបងហ៊ានបានច្បាស់ហ្នុង ចេញគ្រប់ច្រកហ្នុង។

ឡុង ដានីៈ បាទ! ហើយលោកពូតាំងពីយើងទៅនៅលើកោះពូលូវៃថ្មីហ្នឹង មានដែលមកប្រជុំមកអីនៅកំពង់សោម។

អ៊ូ គីមៈ អត់!

ឡុង ដានីៈ ចុះ មន្ទីរកងពលនៅណាទៅ?

អ៊ូ គីមៈ កងពលនៅកំពង់សោម។

ឡុង ដានីៈ ប៉ុន្តែអត់ដែលមកកន្លែងមន្ទីរកងពលទេ។

អ៊ូ គីមៈ អត់!

ឡុង ដានីៈ អត់ដែលសោះ?

អ៊ូ គីមៈ បាទ! ព្រោះបើយើងកូនទាហាន។

ឡុង ដានីៈ អើម! ដែលមកលេងផ្ទះអីដែលអត់?

អ៊ូ គីមៈ អត់! សូន្យពិន្ទុ ។ ឃើញដីគោកគឺអត់ ស្រីញីគឺអត់ អត់ទាំងអស់ ។ អត់ទាំងអស់ ។ ហែលតែទឹកព្រឹកៗ រមាស់ចង់ងាប់ហើយ ។

ឡុង ដានីៈ ហែលតែទឹក?

អ៊ូ គីមៈ បាទ! គេដាក់ឲ្យហែលទឹក គេជិះទូកទម្លាក់ក្នុងទឹក ។

ឡុង ដានីៈ រួចចុះ យើងហាត់រៀនហែលទឹកអីហ្នឹងរាល់តែថ្ងៃទៅ?

អ៊ូ គីមៈ រាល់ថ្ងៃ ។ ព្រឹកគេឲ្យហែលទឹក ហើយថ្ងៃឡើងគេឲ្យចាប់ឈ្លើងសមុទ្រយកឲ្យភ្ញៀវចិន ។ យើងចុះចាប់ឈ្លើងសមុទ្រឲ្យ យើងគ្មានសិទ្ធិហូបទេ តែយើងចាប់ ឈ្លើងសមុទ្រយកឲ្យគេ ។

ឡុង ដានីៈ យើងបានតែចាប់ឲ្យគេ យើងចាប់ទុកហូបអត់បាន?

អ៊ូ គីមៈ អត់បាន! អត់មានសិទ្ធិអីទាំងអស់ ។

ឡុង ដានីៈ អាឈ្លើងសមុទ្រប៉ុណ្ណាទៅ?

អ៊ូ គីមៈ ប៉ុនកំភួនជើង ។

ឡុង ដានីៈ ធំៗ ។

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ចាប់ម៉េចបាន? ហ្នឹងធ្វើម៉េច?

អ៊ូ គីមៈ វាត្រដរទេ វាអត់ត្រដរទេ គើមៗដូចខ្នងអញ្ចឹង ។

ឡុង ដានីៈ នៅក្នុងទឹក ឬនៅលើគោកអាហ្នឹង?

អ៊ូ គីមៈ នៅក្នុងទឹក ។ ក្នុងទឹក ទឹកលិច លិចក្បាល ប្រមុជចាប់ ។

ឡុង ដានីៈ មើលឃើញ?

អ៊ូ គីមៈ ឃើញ! ប៉ុនៗ ។

ឡុង ដានីៈ ហើយទៅយើងចាប់វាមក ។

អ៊ូ គីមៈ ចាប់យកមកដាក់ក្នុងធុងមក ។ ហើយយកទៅដល់ផ្ទះយើងដាំទឹកឲ្យក្តៅ ដាំទឹកឲ្យក្តៅ ចាប់ហើយវះខ្វាក បោះបញ្ចូលភ្លូកទៅចូលក្នុងទឹកហ្នឹង ហើយយកមកប្រឡាក់ដេះហាល មិនដែលបានហូបទេ ។

ឡុង ដានីៈ ចាប់បានច្រើនទេ?

អ៊ូ គីមៈ ច្រើនណាស់ មិនខ្វះទេអូន ច្រើនណាស់ ។

ឡុង ដានីៈ សម្បូរអញ្ចឹង?

អ៊ូ គីមៈ បាទ! សម្បូរណាស់ ។

ឡុង ដានីៈ អាហ្នឹងឆ្ងាញ់ឈ្មើងហ្នឹង?

អ៊ូ គីមៈ យី! អាហ្នឹងបានតែចំណីអ្នកធំ ចំណីអ្នកកូនទាហានកំពេកកំពុកហូបមិនបានទេ ។

ឡុង ដានីៈ អត់ដែលដឹងដែរ លោកពូធ្លាប់ហូបទេ?

អ៊ូ គីមៈ បាទ! បានតែចាប់បាន តែការហូបអត់មានទេ ។

ឡុង ដានីៈ អញ្ចឹងការងារនៅលើកោះហ្នឹង ព្រឹកឡើងហាត់ហែលទឹក?

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ ហែលទឹក លោកពូថាមានដាក់ដុំថ្មនៅក?

អ៊ូ គីមៈ ដុំថ្មមួយគីឡូទៀត ។

ឡុង ដានីៈ នៅកហ្នឹងហែលយ៉ាងម៉េច ហែលរយៈពេលប៉ុន្មាន?

អ៊ូ គីមៈ ទេ! ដឹកយើងតាំងពីម៉ោង៧អញ្ចឹង គេដឹកតាមកាណូតអញ្ចឹង ដល់នេះទៅដល់កំណត់គេ គេឲ្យលោតចុះ ១ ២ ៣ ឡើងមកកោះវិញ ។

ឡុង ដានីៈ យើងហែលមកកោះមក?

អ៊ូ គីមៈ បាទ! ហើយអ្នកខ្លះរមួលក្រពើអីអញ្ចឹងទៅ អ្នកខ្លះទៀតគ្រាន់តែ មកដល់ឡើងដីខ្សាច់ក៏សន្លប់ ចុះឆ្ងាយណាស់មិនតិចទេ ប៉ុន្តែសំណាងល្អហើយទឹកសមុទ្រវា មានខ្សែរលកដើតលិចដើតកើត បើដូចទឹកសាបហែលអត់រួចទេ ១០គីឡូហ្នឹងអត់រួចទេ ។

ឡុង ដានីៈ ១០គីឡូ?

អ៊ូ គីមៈ បាទ!

ឡុង ដានីៈ អញ្ចឹងហែល១០គីឡូហ្នឹង ហែលរយៈពេលប៉ុន្មានម៉ោងបានទៅដល់?

អ៊ូ គីមៈ យូរដែរ ប្រហែលជា ។

ឡុង ដានីៈ ២-៣ម៉ោង?

អ៊ូ គីមៈ ២-៣ម៉ោង ខ្ទើកៗនៅហ្នឹងហើយ ។ នេះវាបានទឹកសមុទ្រវាមាន រលកចុះរលកឡើងបើថាដូចទឹកសាបហ្នឹងគឺអត់ ។

ឡុង ដានីៈ ចុះថាអ្នករមួលក្រពើអ្នកអី?

អ៊ូ គីមៈ រមួលក្រពើលិចស្លាប់បាត់ ។ ទូកគេមកតាមពីក្រោយ គេស្រង់អាហ្នឹងមកឡើងលើទូកមក ។

ឡុង ដានីៈ ប៉ុន្តែហាត់រាល់តែថ្ងៃ ធ្វើអញ្ចឹងរាល់តែថ្ងៃ?

អ៊ូ គីមៈ បាទ! ហាត់រាល់តែថ្ងៃ ។

ឡុង ដានី៖ ដល់ពេលរាល់ថ្ងៃទៅយើងហែល១០គីឡូ ម៉េចធម្មតាឬក៏?

អ៊ូ គីម៖ ចា៎ទ! ធម្មតា ។ វាអត់អីទេ ។

ឡុង ដានី៖ ហែលភ័យហែលអីហើយ?

អ៊ូ គីម៖ ១០គីឡូមិនអីទេ ។

ឡុង ដានី៖ ដូចថា២យប់ ២ថ្ងៃអី យើងអាចហែលកើតអត់នៅក្នុងសមុទ្រ? ប្រសិនជាមានបញ្ហាអី ក្នុងសមុទ្រដល់២យប់ ២-៣ថ្ងៃ ។

អ៊ូ គីម៖ មិនអាចទប់បានទេអូន ។ មិនអាចទប់បានទេ ។

ឡុង ដានី៖ បើយើងមានអី?

អ៊ូ គីម៖ ត្រឹម១ម៉ោង ។ ៣-៤ម៉ោងអីបាន ។

ឡុង ដានី៖ ៣-៤ម៉ោងបាន?

អ៊ូ គីម៖ ចា៎ទ! បើថាចូលដល់២យប់ ២ថ្ងៃ ។ ទប់អត់ជាប់ទេ វាខ្សោយ ។ ហើយម្យ៉ាងទឹកសមុទ្រវាវៃ ចេះតែវៃ ។

ឡុង ដានី៖ បើមាន បើយើងមានដូចជាកាដុង ដូងអី?

អ៊ូ គីម៖ អ៊ូ បាន! អាហ្នឹងបាន អត់អីទេ ។

ឡុង ដានី៖ ដូងកែដែរ ដូងហ្ន៎?

អ៊ូ គីម៖ ចា៎ទ! ពូកែដែរ ។ ខ្ញុំទៅមុនដំបូងដល់ហើយ ប្រវត្តិអណ្តែតទៅ កង់ឡានមួយ កាន់តែឯង ខ្លាចអើយខ្លាច ចុះបើលេងឡើងខ្ពស់អញ្ចេះ ទម្លាក់មកអញ្ចេះ ។ ទៅដល់ក្រោយខ្ញុំលែងចេះពុល ចេះអីអស់លីង ប្អូនអើយ ប្រវត្តិវេទនាណាស់ ។

ឡុង ដានី៖ ចុះ! ពេលដែលឆ្នាំ៧៩ ពេលដែលគេឲ្យប្រមូលអីវ៉ាន់រៀបចំអីហ្នឹង ពូអត់ដឹងថាយួនចូលមកដល់កំពង់សោមទេ?

អ៊ូ គីម៖ អត់! អត់ដឹងទេ ។

ឡុង ដានី៖ ហើយយ៉ាងម៉េចពូអាចរៀបរាប់កាលហ្នឹង?

អ៊ូ គីម៖ ហ្នឹងម៉ោង១ ម៉ោង១យប់ គេចាប់ទា ចាប់មាន់មួយចំនួន គេចាប់បាន គេថា ពួកយើងរៀបចំ ហើយថារៀបចំស្អីគេ? រៀបចំមក មិនបាច់មាត់ទេ គិចដឹង ហើយដល់ម៉ោង១ កប៉ាល់ទៅកំពង់សោមទៅយកមកនៅកន្លែងដែហ្នឹង ឡើងលើកប៉ាល់ព្រឹបយួនមកដល់កងគេង ។

ឡុង ដានី៖ ពីណាអ្នកទៅប្រាប់ឲ្យរៀបចំថាមិនបាច់មាត់ទេ?

អ៊ូ គីម៖ មេកងគេ មេកងហាហ្នឹង ។

ឡុង ដានី: ចា៎ះ!

អ៊ុំ គីម: ឲ្យគេរៀបចំ។

ឡុង ដានី: ពេលហ្នឹងពូអត់មានបានតួនាទីអីទេ? ពី៧៥ដល់៧៩អត់ទេ?

អ៊ុំ គីម: អត់ទាន់មានទេអូន។

ឡុង ដានី: ដល់ពេលឲ្យយើងរៀបចំអញ្ចឹង ទាំងអីវ៉ាន់ ទាំងមាន់ ទាំងទាចាប់ដាក់នៅហ្នឹង ទាំងអស់?

អ៊ុំ គីម: ចា៎ះ! ចាប់បានភាគតិចណាស់ មិនចាប់បានច្រើនទេ ចាប់បានភាគតិច។ ខ្ញុំមិនដឹងថាចាប់ស្អីគេផង? មិនដឹងអីផង គេថារៀបចំៗស្អាយតែកាំភ្លើងឡើងមកកន្លែងដែមក។

ឡុង ដានី: ចុះពូមានប្រសាសន៍មិញ ថាមានចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោ?

អ៊ុំ គីម: អ៊ូ៎! ច្រើនណាស់។

ឡុង ដានី: ហើយ ច្រើនហើយលោកពូថាហូបចុកអត់គ្រប់គ្រាន់ទៀត?

អ៊ុំ គីម: មិនអាចហូបគ្រប់ទេអូន ព្រោះគ្នា១០០នាក់ដាង អូនឯងគិតទៅ១០០នាក់ ហើយបើសិនជាយើងយកមាន់ទាហ្នឹងហូបរាល់ថ្ងៃ ទប់វាមិនជាប់ទេ។ ដល់តែមានត្រីជំនួយខ្លះ ប៉ុន្តែតាមការពិតច្រើន ច្រើនហើយ បើជ្រូកវិញ មាន់វិញគ្រប់កន្លែងទាំងអស់ តែវាមិនអាចគ្រប់គ្រាន់ដូចយើងហូបរាល់ថ្ងៃបានទេ។ បើមួយអាទិត្យម្តងគឺណែណនណាស់ច្បាស់លាស់ណាស់។

ឡុង ដានី: ចុះដូចត្រីពួកនេសាទថៃមក យើងយកបាន យើងគ្រាន់តែធ្វើត្រីប៉ុន្មាន?

អ៊ុំ គីម: កន្លះខែ!

ឡុង ដានី: កន្លះខែហ្នឹង យើងហូបម៉េចអស់? មួយឆ្នាំ យើងហូបមិនអស់ផង។

អ៊ុំ គីម: ទុកចោលទៀត ខារចោលទៀត។ គ្មានអ្នកណាហូបអស់ទេ។ នៅក្នុងឃ្លាំង និយាយពីខារចោលដូចអីអញ្ចឹង។

ឡុង ដានី: អត់បញ្ជូនមកកំពង់សោមទេ?

អ៊ុំ គីម: អត់ទេ! ត្រីហ្នឹង គេសម្រាប់ផ្គត់ផ្គង់ខាងនេះហ្នឹង ប៉ុន្តែគ្មាននរណាហូបកើតទេអូន។ ធម្មតាហូបរាល់ថ្ងៃ ត្រីទាំងឃ្លាំង។ គេប្រលាក់អំបិល គេទុកក្នុងឃ្លាំងហ្នឹង ខារនៅហ្នឹងហូបអត់កើតទេ។

ឡុង ដានី: វាច្រើនពេក។

អ៊ុំ គីម: ច្រើនពេក!

ឡុង ដានី: ហើយអត់បានសម្ងួតវាត្រឹមត្រូវ។

អ៊ូ គីមៈ ប៉ាទ! អត់បានសម្លូតត្រឹមត្រូវ ខ្ញុំធ្វើត្រីចង់ងាប់ហើយ ត្រីហ្នឹងធ្វើ របកដៃរបកជើងអស់ ។

ឡុង ដានីៈ ហើយយ៉ាងម៉េចដែលឲ្យរៀបចំអីមក ពូមកចេញមកត្រឹមណាវិញ?

អ៊ូ គីមៈ ខ្ញុំឡើងកប៉ាល់មក បានដឹងគេចុចកាំភ្លើងធំចោល ១០៥កាំភ្លើងធំហ្នឹង គេចុចចោល គេបំផ្លាញចោល ដល់ហើយគេបរមកចម្លងគោ ដល់បរមកចម្លងគោអញ្ចឹង គ្រាន់តែមកដល់ចម្លងគោ គេថាយើងរៀបចំ កម្លាំងទៅវៃនៅកងគេង ។ ខ្ញុំក៏រៀបចំកាំភ្លើងព្រួស១១១ ។ មួយសន្ទុះអត់ទៅទេ ។ មួយសន្ទុះវិញក៏ដឹកយើងទៅចម្លងគោហួសស្ទឹងហាវហ្នឹង មិនទៅនោះ អូនឃើញទេ ។ អើម! ដល់លើកោះហ្នឹងវៃគ្នា វ៉ៃពេញផងឹតឈឹង គ្រាន់តែឡើងលើកោះភ្លាមវៃគ្នាវ៉ៃ កាលហ្នឹងនៅក្មេងផង គេធ្វើបាបដល់ហើយ ស្រេចតែគេប្រើ កាំភ្លើង គេឲ្យកាន់ដល់ទៅកាំភ្លើង២ ។ មីគីយើរបស់អាមេរិចជើងបីហ្នឹងមួយលី ជើងបីអាធំ ជើងបីគ្រាប់មួយឡាំង ។ អើម! ហើយAK មួយដើមកាលហ្នឹងវានៅក្មេងនៅកម្លាំង ។

ឡុង ដានីៈ ហើយម៉េចទៀតទៅ ពេលវ៉ៃនៅហ្នឹងហើយ?

អ៊ូ គីមៈ វៃហ្នឹងហើយ វៃគ្នាមួយឆុលអញ្ចឹងមក ខ្ញុំក៏ដកតាមព្រៃពីចម្លងគោ ចូលមកព្រៃមកដំណាក់តាយឹងស្ទឹមក កន្លែងតាណៃតាផាតយាយខាងផងទែន ស្រែអំបិលនេះមកគេចៗមកបានចូលអីចឹងមកត្រាត ខាងខ្លងយៃ៉នេះមកត្រាត ខាងខ្លងយៃ៉ហ្នឹង បានថៃហ្នឹងគេចាប់បញ្ជូនមកខាងនេះវិញមកខាងហ្នឹង កំសត់ណាស់អូន ។

ឡុង ដានីៈ ដល់ពេលអញ្ចឹង ដល់ពេលហូរហែរអញ្ចឹង ពេលហ្នឹងពូបែកខ្ញែកគ្នាពីកងពល១៦៨ វៃបែកហើយ?

អ៊ូ គីមៈ បែកហើយ បែកអស់ហើយ ហើយរបួសផង អីផង កាលហ្នឹងរបួស ។

ឡុង ដានីៈ ហើយលោកពូថាចេញមកតាមអី តាមត្រាតខ្លងយៃ៉អី មកបានប៉ុន្មាននាក់ទៅ?

អ៊ូ គីមៈ បានគ្នាច្រើនដែរអូន ប៉ុន្តែបែកគ្នាអស់ហើយ អ្នកនៅអន្តភាពហ្នឹង ។

ឡុង ដានីៈ ប្រធានអីណា ប្រធានវរសេនាតូច?

អ៊ូ គីមៈ អ៊ូ! បែកអស់ហើយ គ្មានសល់ទេ ។

ឡុង ដានីៈ ប៉ាទ!

អ៊ូ គីមៈ បែកខ្ញែកគ្នា ខ្ញុំរបួសផងអីផង ដើរដាច់បាយ ដាច់អី ម្យ៉ាងឈឺហើម ។

ឡុង ដានីៈ ប៉ុន្មានខែទៅបានមកដល់ត្រាតខ្លងយៃ៉?

អ៊ូ គីមៈ ១ខែជាង ។

ឡុង ដានី៖ ១ខែដាន?

អ៊ូ គីម៖ បាទ! ១ខែដាន ។

ឡុង ដានី៖ ហើយយ៉ាងម៉េចទៀតទៅ?

អ៊ូ គីម៖ និយាយពីមកតាមផ្លូវ ពុលអាផ្សិតនោះ ។ ឃើញផ្សិតស១ ដាច់បាយ ទៅដកអាផ្សិតហ្នឹងមកធ្វើហូប ពុលងាប់អស់៦-៧នាក់ទៀតទៅ ។ ដាច់បាយ ហើយវេទនាណាស់ ។ ប្រវត្តិក្នុងឆាកជីវិតនេះដល់ហើយ ។

ឡុង ដានី៖ ហើយម៉េចដល់ពេលចេញពីហ្នឹងមក ណាមកដល់ណាទៀតទៅ?

អ៊ូ គីម៖ ចេញពីនេះហ្នឹង ថៃគេបញ្ជូនមក មកខាងខ្មែរ-កំរៀងមក ខ្ញុំក៏មកខ្មែរមកកំរៀងមក មកគីឡូ១៣ហ្នឹងមក នៅហ្នឹងរហូតមកទៅ ។

ឡុង ដានី៖ ចុះពេលលោកពូមកដល់គីឡូ១៣ យើងមកនៅអង្គភាពកងពលអីណាទៀតទៅ?

អ៊ូ គីម៖ ៤០៥ ។

ឡុង ដានី៖ កាលហ្នឹងពេលឆ្នាំ៧៩ហ្នឹង កងពល៤០៥មានហើយឬក៏អត់ទាន់មានទេ?

អ៊ូ គីម៖ បាទ! កងពល៤០៥នេះឯង ។ ៤០៥ខាង! កងពល១៦៤ហ្នឹង ប៉ុន្តែអង្គភាពតូចគេ ៤០៥នេះ ។

ឡុង ដានី៖ បាទ!

អ៊ូ គីម៖ ១៦៤ហ្នឹងគឺជាកងពលស៊ីសូផុនខាងត្បូងហ្នឹងដែលអង្គភាពតូចគេ៤០៥ ។

ឡុង ដានី៖ ៤០៥!

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ កាលហ្នឹងពីណាប្រធាន?

អ៊ូ គីម៖ មានណា មានតាកនហ្នឹង ។

ឡុង ដានី៖ តាកន!

អ៊ូ គីម៖ អើ!

ឡុង ដានី៖ តាកន គាត់ប្រធានកងពលណា?

អ៊ូ គីម៖ ១៦៤ហ្នឹង ។

ឡុង ដានី៖ ១៦៤ ក្រែងកងពលតាមុត?

អ៊ូ គីម៖ ៤០៥ កងពលហ្នឹង ។

ឡុង ដានី៖ ចុះកងពល៣២០ម៉េច?

អ៊ូ គីម៖ អូ! ៣២០ហ្នឹង មិញនិយាយខុស ។

ឡុង ដានី៖ មិញនិយាយខុស មិនមែន១៦៨ទេ ៣២០ កងពលធំគេ៣២០?

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ បាទ! របស់ នី កន ។ ហើយដល់ពេលមានកងពលធំ៣២០ហ្នឹង មានកងពលតូច ៤០៥ ទៀត?

អ៊ូ គីម៖ មានអង្គភាព៤០៥អញ្ចេះទៀតទៅ ។

ឡុង ដានី៖ បាទ!

អ៊ូ គីម៖ មាន៤០៤អីអញ្ចេះទៀតទៅ ។

ឡុង ដានី៖ ៤០៥ ។ ចុះ៩៤៨អី?

អ៊ូ គីម៖ ៩៤៨អី?

ឡុង ដានី៖ ៧?

អ៊ូ គីម៖ ហ្នឹងមានតាមរចនា ។

ឡុង ដានី៖ ចុះកងពលខាងកំរៀង?

អ៊ូ គីម៖ ហ្នឹងខ្ញុំអត់ដឹង ។

ឡុង ដានី៖ របស់តា គង់ ។

អ៊ូ គីម៖ បាទ! ខ្ញុំអត់ដឹងទេ ។

ឡុង ដានី៖ អត់ដឹងទេ?

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ ហើយលោកពូនៅក្នុង៤០៥ហ្នឹងទៅ?

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ ប្រធាន៤០៥ពីណាគេ?

អ៊ូ គីម៖ កាលហ្នឹង ខ្មោចតាម៉ុច គាត់នៅ ។ តាម៉ុច យើងហ្នឹង ។

ឡុង ដានី៖ បាទ ។

អ៊ូ គីម៖ ហើយដល់តាម៉ុច គាត់ស្លាប់បាត់ទៅឥឡូវ ។ ហើយតាឈន, តាម៉ុច តាគាត់ស្លាប់បាត់ទៅ តាឡាំង ក៏ស្លាប់អស់ឥឡូវ ។

ឡុង ដានី៖ អើម! តាម៉ុច, តាឡាំង ។

អ៊ូ គីម៖ តាឡាំង ។

ឡុង ដានី៖ ហើយលោកពូនៅក្នុង៤០៥ហ្នឹងរហូត?

អ៊ូ គីម៖ បាទ!

ឡុង ដានី: ហើយលោកពូរៀបការឆ្នាំណាទៅ?

អ៊ូ គីម: អ៊ូ! ការតាំងពី៧៩ ។

ឡុង ដានី: ការនៅ៧៩!

អ៊ូ គីម: បាទ!

ឡុង ដានី: ការនៅ?

អ៊ូ គីម: នៅប្រទេសថៃ ។

ឡុង ដានី: ការនៅប្រទេសថៃ?

អ៊ូ គីម: បាទ! នៅស្រះកែវប្រទេសថៃ ។

ឡុង ដានី: ចុះលោកពូមិញមានប្រសាសន៍មិញថា រត់មិញហ្នឹងមកដល់កន្លែងខេត្តត្រាត ខេត្តអីតែ១ខែបានដល់គីឡូ១៣ ហើយលោកពូការតាំងពី៧៩ ការពេលណាដែរ?

អ៊ូ គីម: កាលទៅដល់ស្រះកែវ រឿងហ្នឹងវាកំប៉ិចកំប៉ុកម្ដងបន្តិច និយាយទៅ វាមិនបានល្អិតគ្រប់ជ្រុងជ្រោយទេ ។

ឡុង ដានី: បាទ!

អ៊ូ គីម: មកពីត្រាតមកនៅគីឡូ១៣នេះ ហើយវៃគ្នាប្រទុងប្រទាំងៗហ្នឹង ខ្ញុំក៏ទៅនៅចក្រី ។ អើម! ទៅនៅចក្រីហ្នឹង ប៉ារាំងយកពីចក្រីហ្នឹង ទៅនៅស្រះកែវ ត្រឡប់ពីស្រះកែវទៅវិញ ខ្ញុំបានចំការចេកនេះ មកនៅចំការចេកនេះវិញ ហើយខ្ញុំនៅតាមហ្នឹងរហូតមុិញវាកំប៉ិកកំប៉ុកច្រើន ។

ឡុង ដានី: ហើយលោកពូការ ការពេលបារាំងយកទៅហ្នឹងទេ?

អ៊ូ គីម: បាទ!

ឡុង ដានី: ហើយកាលហ្នឹង ក្រែងលោកពូនៅកងទ័ព ម៉េចបារាំងយកទៅ? ហើយក៏ឈប់ពីកងទ័ព?

អ៊ូ គីម: ខ្ញុំ ពេលហ្នឹងខ្ញុំត្រូវបារាំងយកទៅ ខ្ញុំឈប់ហើយ ។

ឡុង ដានី: អើម!

អ៊ូ គីម: ខ្ញុំក៏ដាច់ខ្សែរយះអស់ទៅ ។

ឡុង ដានី: ដល់ពេលឈប់ទៅជួបមីងនៅស្រះកែវ?

អ៊ូ គីម: បាទ! នៅស្រះកែវ!

ឡុង ដានី: អើម!! ហើយម៉េចបានការ បើពូទៅដល់ហ្នឹង?

អ៊ូ គីមៈ	អឺម! វាពិបាកពេក ម្យ៉ាងម្នាក់ឯងមើលទៅពិបាកអត់មានអ្នកណាទីពឹង មានឪពុកម្ដាយឯណា ឪពុកម្ដាយនៅស្រុកទាំងអស់គ្នា ។ ឃើញគ្នាអាណិតអាសូរ ធ្វើអីចេះតែ ។

ឡុង ដានីៈ	ប្រពន្ធលោកពូ គាត់ឈ្មោះអី?

អ៊ូ គីមៈ	សឹម សេង ។

ឡុង ដានីៈ	សឹម សេង ។ វណ្ណៈ សួរហើយមិញ ។

អ៊ូ គីមៈ	អឺម!

ឡុង ដានីៈ	សួរនៅ?

សុខ វណ្ណៈ	សួរហើយ!

ឡុង ដានីៈ	អញ្ចឹង! ប្រពន្ធរបស់លោកពូ គាត់ឈ្មោះ សឹម សេង?

អ៊ូ គីមៈ	បាទ!

ឡុង ដានីៈ	ហើយប្រពន្ធលោកពូ អ្នកស្រុកណាដែរ?

អ៊ូ គីមៈ	នៅកំពតដែរ ។

ឡុង ដានីៈ	នៅកំពតជាមួយគ្នា ។

អ៊ូ គីមៈ	បាទ!

ឡុង ដានីៈ	អឺម! នៅស្រុកកំណើតជាមួយគ្នា ភូមិឃុំ?

អ៊ូ គីមៈ	អត់ទេ! ខ្ញុំនៅទូកមាស ។

ឡុង ដានីៈ	អូ! លោកពូ នៅទូកមាស ។ ប្រពន្ធនៅ?

អ៊ូ គីមៈ	នៅឈូក!

ឡុង ដានីៈ	នៅឈូក!

អ៊ូ គីមៈ	បាទ!

ឡុង ដានីៈ	ពូអ្នកភូមិអី នៅទូកមាស?

អ៊ូ គីមៈ	នៅភូមិសូរិយា ។

ឡុង ដានីៈ	ភូមិសូរិយា! ឃុំអីគេហ្នឹង?

អ៊ូ គីមៈ	ឃុំត្នោតចុងស្រង់ ។

ឡុង ដានីៈ	ត្នោតចុងស្រង់ ។

អ៊ូ គីមៈ	ស្រុកបន្ទាយមាស ។

ឡុង ដានីៈ	ស្រុកបន្ទាយមាស ។ ដល់ពេលប្រពន្ធអ្នកខាងឈូកវិញ?

អ៊ូ គីមៈ	បាទ!

ឡុង ដានីៈ	ហើយដល់ពេលលោកពូ ការហើយបានមក?

អ៊ូ គីមៈ	ដល់ពេលការហើយ បានមកនៅនេះចំការចេកនេះ។

ឡុង ដានីៈ	ប៉ុន្តែមកចូលជាទាហានវិញអត់ទេ?

អ៊ូ គីមៈ	បាទ មក! ប្រជាជនទេ គេបង្ខំយើងឲ្យធ្វើការដូចទាហានអញ្ចឹង។ ធ្វើអី ដឹកជញ្ជូនគ្រាប់ទៅមុខ ទៅក្រោយ ចាក់ចម្រូង កាប់ក្រឡុកដាក់ប្រឡាយ គឺមានរហូត។

ឡុង ដានីៈ	កាលហ្នឹង ពូអត់មានត្រូវរបួសអីទេ ឬក៏ត្រូវដែរ?

អ៊ូ គីមៈ	កាលហ្នឹង ខ្ញុំអត់ទាន់ត្រូវទេ។ អត់ទាន់ត្រូវទេ កាលហ្នឹងនៅស្អាតចេសហ្នឹង។

ឡុង ដានីៈ	អើម!

អ៊ូ គីមៈ	បើយើង ថ្ងៃហ្នុំ! អ្នកដែលនៅថ្ងៃគេឲ្យដាក់ចម្រូង ចិតចម្រូង បិទចម្រូងហ្នឹង។ ហើយអ្នកខ្លះដឹកជញ្ជូន។ ខ្ញុំហ្នឹងហើយដឹកជញ្ជូនឆ្លាយខត្តុង យកគ្រាប់ យកអង្ករទៅម្តងៗ។

ឡុង ដានីៈ	នៅក្នុងអង្គភាព៨០៥?

អ៊ូ គីមៈ	បាទ! កន្លែងណាប្រជាជននៅតាមផ្លូវនេះត្រូវតែធ្វើការងារហ្នឹងដែរ។

ឡុង ដានីៈ	មានកូនមានចៅនៅពេលហ្នឹង?

អ៊ូ គីមៈ	កាលហ្នឹងដូចអត់ទាន់មានទេ។

ឡុង ដានីៈ	អត់មានទេ។

អ៊ូ គីមៈ	អត់ទាន់មានទេ។ ហើយគេអត់ឲ្យខ្ញុំធ្វើទ័ពទេកាលហ្នឹង ដល់ខ្ញុំមកពីនោះវិញ គេអត់ឲ្យខ្ញុំកាន់កាំភ្លើងកាន់អីទេ។ ដល់ខ្ញុំ មូលហេតុដែលគេមិនឲ្យខ្ញុំកាន់កាំភ្លើង ខ្ញុំចេះតែរិះគន់គេ រិះគន់ថ្នាក់ដឹកនាំមួយចំនួនហ្នឹង ឃើញខ្ញុំទៅទាក់ទងថៃ ទិញអំបិល ទិញប្រហុក គេថាខ្ញុំទៅយកគ្រាប់កាំភ្លើងយកទៅលក់ឲ្យថៃ ដល់នេះខ្ញុំចេះតែលេងវិញទៅ គេខឹងខ្ញុំ គេអត់ហ៊ានឲ្យកាំភ្លើងខ្ញុំកាន់ទេ។

ឡុង ដានីៈ	ខាងកងពល ខាងកង..?

អ៊ូ គីមៈ	បាទ! ខ្មែរក្រហមហ្នឹង សួរទៅ តែមេធំៗមិនហ៊ានឲ្យខ្ញុំកាន់។

ឡុង ដានីៈ	តាកន អីហ្នឹង?

អ៊ូ គីមៈ	អត់ទេ! មិនគាវជាមួយ តាកន ទេ។ ជាមួយ តាឈន ក្បាលធំ តាម៉ិច ហ្នឹង។ តាឈន ហ្នឹង

ឡុង ដានី: ហើយលោកពូនៅធ្វើខាងហ្នឹងរហូតដល់ពេលណាបាន ដូចខាង៨០៥នៅខាងចំការចេក ខាងអីហ្នឹង?

អ៊ូ គីម: បាទ! នៅហ្នឹងរហូតដល់ ហើយកាលហ្នឹងអត់ទាន់ចប់ទេ សង្គ្រាមអត់ទាន់ចប់ទេៗ នៅខ្មែរនឹងខ្មែរហ្នឹងមួយគន្ទាក់ទៀតៗ ដូច្នោះខ្ញុំនឹកឃើញថាពិបាកស្តាយកូន ស្តាយចៅ ខ្ញុំក៏សម្រេចចិត្តទៅស្រុកខ្មែរបាន៣ឆ្នាំៗ

ឡុង ដានី: ឆ្នាំណាលោកពូទៅ?

អ៊ូ គីម: ឆ្នាំ៩១ៗ

ឡុង ដានី: ៩១ លោកពូចេញពីហ្នឹងទៅ ឬក៏លោកពូទៅជំរំសិនៗ

អ៊ូ គីម: មាតុភូមិនិវត្តន៍ គេចេញឆ្នាំប៉ុន្មាន?

ឡុង ដានី: ឆ្នាំ៩២!

អ៊ូ គីម: ៩២ៗ

ឡុង ដានី: ៩២ ៗ

អ៊ូ គីម: ៩២ហ្នឹងហើយ!

ឡុង ដានី: មុនបោះឆ្នោត!

អ៊ូ គីម: បាទ! ហ្នឹងហើយ!

ឡុង ដានី: កាលហ្នឹង លោកពូចេញពីហ្នឹង លោកពូបានទៅជំរំហើយ ហើយបានគេយកពីជំរំទៅធ្វើមាតុភូមិទៅស្រុកហ្នឹង?

អ៊ូ គីម: បាទ!

ឡុង ដានី: លោកពូទៅចេញពីណាទៅ ចេញពីកន្លែង?

អ៊ូ គីម: ចេញពីទីនេះទៅចូលទៅជំរំហើយៗ គេបញ្ជូនពីជំរំហ្នឹងទៅស្រុកខ្មែរៗ រួចហើយខ្ញុំត្រលប់ទៅស្រុកៗ

ឡុង ដានី: ទៅជំរំណា?

អ៊ូ គីម: សាយអេចៗ

ឡុង ដានី: សាយអេច!

អ៊ូ គីម: បាទ!

ឡុង ដានី: ពីហ្នឹងទៅច្រើនទេ ឬក៏ទៅតែពូទេ?

អ៊ូ គីម: ទៅច្រើនណាស់អូន ទៅច្រើនណាស់ៗ

ឡុង ដានី: ទៅច្រើន!

អ៊ូ គីមៈ ចា៎ស! ដប់សឹងតែទាំងដប់ហ្នឹង ។

ឡុង ដានីៈ ចា៎ស! ហើយទៅបាន៣ឆ្នាំ ។

អ៊ូ គីមៈ ទៅ៣ឆ្នាំត្រលប់មកវិញ ។

ឡុង ដានីៈ ៣ឆ្នាំត្រលប់មកវិញឆ្នាំណា?

អ៊ូ គីមៈ ៩២, ៩៣, ៩៤, ៩៥ ។

ឡុង ដានីៈ ៩៥!

អ៊ូ គីមៈ ចា៎ស!

ឡុង ដានីៈ ៩៥ត្រលប់មកវិញ?

អ៊ូ គីមៈ ចា៎ស! ត្រលប់មកវិញ ។

ឡុង ដានីៈ ត្រលប់មកនៅភូមិ?

អ៊ូ គីមៈ ចា៎ស! មកនៅភូមិ ។ មកសុំផ្ទះគេ ផ្ទះគេចាបអី?

ឡុង ដានីៈ មកភូមិអូរហ្នឹងហ្ន៎ង ឬក៏ទៅភូមិអី?

អ៊ូ គីមៈ មកភូមិអូរ អាកន្លែងផ្ទះនៅហ្នឹង ។

ឡុង ដានីៈ ភូមិអូរឃុំសន្តិភាព ។ កាលហ្នឹង បានកូនប៉ុន្មានហើយ ពេលពូធ្វើមាតុភូមិនិវត្តន៍?

អ៊ូ គីមៈ ខ្ញុំបានកូន២ហើយ ។ នៅបានកូន២ហើយ ។

ឡុង ដានីៈ ហើយត្រឡប់មកវិញបាន បានកូនប៉ុន្មានទៀត?

អ៊ូ គីមៈ កូនទាំងអស់៦ទេ ចាំមិនសូវបានទាំងអស់ ។

ឡុង ដានីៈ កូន៦ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អ៊ូ គីមៈ ស្រីទាំងអស់ ។

ឡុង ដានីៈ ស្រីទាំងអស់!

អ៊ូ គីមៈ កាលណាទៅលេង ប៉ុនគ្នាទាំងអស់ ។

ឡុង ដានីៈ ហើយពូចូលធ្វើការនៅឃុំជាជំទប់ទី២ហ្នឹងបានប៉ុន្មានឆ្នាំហើយ?

អ៊ូ គីមៈ បាន២អាណត្តិហើយអូន ។

ឡុង ដានីៈ បាន២អាណត្តិហើយ!

អ៊ូ គីមៈ ២អាណត្តិហើយ ។

ឡុង ដានីៈ ហើយអាណត្តិមុនគណៈបក្សណា? គណៈបក្សសមរង្ស៊ី?

អ៊ូ គីមៈ អត់ទេ! កាលហ្នឹង លើកមុននោះ គណៈបក្ស រណឫទ្ធិនោះ ។

ឡុង ដានីៈ ខាងគណៈបក្ស

អ៊ូ គីម៖ ញ៉ើក បុនឆៃ ។

ឡុង ដានី៖ ហុនស៊ីនប៉ិច ។

អ៊ូ គីម៖ ហ៊ុនស៊ីនប៉ិច ។

ឡុង ដានី៖ បាទ!

អ៊ូ គីម៖ ហើយដល់ក្រោយបានមញ សមរង្ស៊ី ។

ឡុង ដានី៖ មកសង្គ្រោះជាតិ ។ សមរង្ស៊ី សង្គ្រោះជាតិ?

អ៊ូ គីម៖ បាទ

ឡុង ដានី៖ បាន២អាណត្តិហើយលោកពូ?

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ បាទ! ដូចខ្ញុំរំខានពូច្រើនហើយ អីចឹងខ្ញុំអរគុណលោកពូច្រើនដែលបានផ្តល់បទសម្ភាសន៍ ជាមួយខ្ញុំជាងមួយម៉ោងហ្នឹង អរគុណច្រើន លោកពូ

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ បាទ!

អ៊ូ គីម៖ អរគុណដែរ ហើយក៏ជូនពរឲ្យអូនទាំងអស់ដែលបានធ្វើការល្អទៅថ្ងៃមុខទៀត ។

ឡុង ដានី៖ ហើយលោកពូអាយុប៉ុន្មានមកដល់សព្វថ្ងៃនេះ?

អ៊ូ គីម៖ អូ! ៥៩ ។

ឡុង ដានី៖ ៥៩ហើយ ។

អ៊ូ គីម៖ បាទ!

ឡុង ដានី៖ អូ! បាទអរគុណច្រើនលោកពូ ។

ចប់